ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅណែនាំ
# ស្ដីពី
# ការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ
Professional Learning Community ( PLC )
# នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ

ខែមីនា ឆ្នាំ២០២១

# បុព្វកថា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដើម្បីធានានូវកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ ក្នុងគោលបំណងប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។ ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រខាងលើក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់លើការកសាងអភិវឌ្ឍធនធានមនុស្សឱ្យមានគុណភាពខ្ពស់សម្រាប់ឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងតម្រូវការទីផ្សារការងារ។ ហេតុដូចនេះហើយ ចាំបាច់ត្រូវការគ្រូឧទ្ទេស គ្រូបង្រៀន អ្នកបំប៉នសមត្ថភាពគ្រូបង្រៀន គណៈគ្រប់គ្រងសាលាគរុកោសល្យ និងគណៈគ្រប់គ្រងសាលារៀនដែលមានសមត្ថភាព និងឧត្តមភាពក្នុងការធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិក្សារបស់សិស្ស។

ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន គោលនយោបាយស្តីពីគ្រូបង្រៀន ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន គោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ ក្របខណ្ឌស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀននិងនាយកសាលា ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន និងសេចក្តីណែនាំប្រតិបត្តិក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន ក្នុងគោលដៅអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន និងនាយកសាលា ដើម្បីបណ្តុះវប្បធម៌រៀនពេញមួយជីវិត។ ក្នុងបរិការណ៍នេះ ការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនៅក្នុងប្រព័ន្ធអប់រំកម្ពុជា ជាការឆ្លើយតបមួយដ៏ចាំបាច់ ដើម្បីបង្កើនសមត្ថភាពបង្រៀនរបស់គ្រូ និងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។

សហគមន៍សិក្សាវិជ្ជាជីវៈជាក្រុមការងារដែលគ្រូបង្រៀនអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំក្នុងក្របខណ្ឌនៃការសិក្សាពេញមួយជីវិតតាមរយៈការសហការ ការចែករំលែក ការវិភាគ ការស្រាវជ្រាវប្រតិបត្តិ និងការឆ្លុះបញ្ចាំងលើការបង្រៀន និងរៀន។ សហគមន៍នេះ ទទួលបានការចាប់អារម្មណ៍ និងអនុវត្តក្នុងប្រព័ន្ធអប់រំទាំងនៅក្នុងពិភពលោក និងបណ្តាប្រទេសក្នុងតំបន់ដូចជាប្រទេសកូរ៉េខាងត្បូង សិង្ហបុរី ថៃ និងម៉ាឡេស៊ីជាដើម។ បន្ថែមពីនេះក្រុមការងារចម្រុះដើម្បីគ្រូបង្រៀននៅក្នុងពិភពលោក (International Task Force on Teachers) ដែលដឹកនាំ និងសម្របសម្រួលដោយអង្គការយូណេស្កូ តម្រូវឱ្យប្រទេសដែលជាសមាជិកប្រែក្លាយការងារបង្រៀនមិនមែនត្រឹមតែជាមុខរបរប៉ុណ្ណោះទេតែជាអាជីព ដើម្បីឱ្យគ្រូបង្រៀនមានសមត្ថភាពវិជ្ជាជីវៈខ្ពស់ និងទទួលបានការគោរពគាំទ្រពីសង្គម។

ក្រសួងអប់រំ យុវជន និងកីឡាសូមលើកទឹកចិត្ត និងសង្ឃឹមយ៉ាងមុតមាំថា គណៈគ្រប់គ្រងសាលាគរុកោសល្យ គណៈគ្រប់គ្រងសាលារៀន គ្រូឧទ្ទេស និងគ្រូបង្រៀននឹងបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ និងជានានិរន្តរភាពនៃការអនុវត្តនៅតាមគ្រឹះស្ថានសិក្សា។

ថ្ងៃ អង្គារ ១០កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# មាតិកា


**១. សេចក្តីផ្តើម** ..... 1
**២. អ្វីជាសហគមន៍សិក្សាវិជ្ជាជីវៈ?** ..... 1
២.១. និយមន័យ ..... 1
២.២. បញ្ញត្តិទូទៅនៃសហគមន៍សិក្សាវិជ្ជាជីវៈ ..... 1
**៣. ដំណើរការសហគមន៍សិក្សាវិជ្ជាជីវៈ** ..... 2
៣.១. សំណួរតម្រង់ទិសសម្រាប់ដំណើរការសហគមន៍សិក្សាវិជ្ជាជីវៈ ..... 2
៣.២. វដ្តនៃការចោទសួរនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ ..... 4
៣.៣. សកម្មភាពពាសំខាន់ៗដែលអាចអនុវត្តបាននៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ ..... 5
**៤. សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គណៈគ្រប់គ្រង** ..... 8
៤.១. សមាសភាព ..... 8
៤.២. តួនាទី និងភារកិច្ច ..... 8
៤.៣. របៀបរបបអនុវត្តការងារ ..... 9
**៥. សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូឧទ្ទេស** ..... 9
៥.១. សមាសភាព ..... 9
៥.២. តួនាទី និងភារកិច្ច ..... 10
៥.៣. របៀបរបបអនុវត្តការងារ ..... 11
**៦. សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូវិទ្យាល័យ និងអនុវិទ្យាល័យ** ..... 12
៦.១. សមាសភាព ..... 12
៦.២. តួនាទី និងភារកិច្ច ..... 13
៦.៣. របៀបរបបអនុវត្តការងារ ..... 13
**៧. សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូបឋមសិក្សា** ..... 14
៧.១. សមាសភាព ..... 14
៧.២. តួនាទី និងភារកិច្ច ..... 15
៧.៣. របៀបរបបអនុវត្តការងារ ..... 16
**៨. ប្រព័ន្ធគាំទ្រសហគមន៍សិក្សាវិជ្ជាជីវៈ** ..... 18
៨.១. អ្នកពាក់ព័ន្ធសំខាន់ៗ ..... 18
៨.២. ប្រព័ន្ធលើកទឹកចិត្តដល់សហគមន៍សិក្សាវិជ្ជាជីវៈ ..... 21
**៩. សេចក្តីសន្និដ្ឋាន** ..... 23

## ១. សេចក្តីផ្តើម

កំណែទម្រង់ការអប់រំ មានគោលបំណងកែលម្អ និងបញ្ចូលវិធីសាស្ត្របង្រៀនថ្មីៗសម្រាប់បង្រៀនសិស្ស ឱ្យមានចំណេះដឹង និងជំនាញ ដើម្បីទទួលបានជោគជ័យនៅក្នុងសង្គមសតវត្សរ៍ទី២១។ ចាំបាច់គ្រូបង្រៀនក៏ត្រូវការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួន ឱ្យស្របទៅនឹងរបៀបរៀន និងបង្រៀនថ្មីៗក្នុងសតវត្សរ៍ទី២១នេះផងដែរ។ នៅក្នុងប្រទេសកម្ពុជា ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀនមិនទាន់មានលក្ខណៈជាប្រព័ន្ធទៀងទាត់នៅឡើយ ដែលធ្វើឱ្យគ្រូបង្រៀននៅកម្រិតសាលារៀន ជួបបញ្ហាប្រឈមដូចជា ការអភិវឌ្ឍវិជ្ជាជីវៈមិនមានលក្ខណៈជាប្រព័ន្ធ មិនមានការពិនិត្យតាមដានត្រឹមត្រូវ និងកង្វះប្រសិទ្ធភាពចំពោះការប្រជុំបច្ចេកទេស។

ការអភិវឌ្ឍវិជ្ជាជីវៈប្រកបដោយប្រសិទ្ធភាព សំដៅដល់ការអភិវឌ្ឍវិជ្ជាជីវៈ ដែលធ្វើឱ្យមានការប្រែប្រួល ជាវិជ្ជមានលើគុណភាពនៃការបង្រៀន និងការរៀន ប្រកបដោយនិរន្តរភាព។ ការរៀនសូត្រជាមួយអ្នកមានអាជីពដូចគ្នា ក្នុងក្របខណ្ឌនៃសហគមន៍សិក្សាវិជ្ជាជីវៈ ជាមូលដ្ឋានគ្រឹះមួយនៃការអភិវឌ្ឍវិជ្ជាជីវៈប្រកបដោយប្រសិទ្ធភាព ពីព្រោះគ្រូបង្រៀន៖

- អភិវឌ្ឍសមត្ថភាពបន្ថែមលើចំណេះដឹងមានស្រាប់ និងបទពិសោធន៍ការងារកន្លងមក
- ចូលរួមក្នុងការរៀនសូត្របែបសកម្ម
- កំណត់នូវប្រធានបទដែលទាក់ទង នឹងបរិបទដែលគ្រូបង្រៀនកំពុងបង្រៀន
- មានកិច្ចសហការរវាងគ្នា
- ដឹកនាំដោយគ្រូបង្រៀនផ្ទាល់ និងមានភាពជាម្ចាស់ក្នុងការរៀនសូត្រ
- បង្កើតឱ្យមានការឆ្លុះបញ្ចាំងដែលមានលក្ខណៈជាប្រព័ន្ធ និងស៊ីជម្រៅ។

## ២. អ្វីជាសហគមន៍សិក្សាវិជ្ជាជីវៈ?

### ២.១. និយមន័យ

**សហគមន៍សិក្សាវិជ្ជាជីវៈ** ជាក្រុមគ្រូបង្រៀន គ្រូឧទ្ទេស និងនាយកសាលា ដែលប្តេជ្ញាធ្វើការងារ រៀនសូត្ររួមគ្នា រៀនសូត្រពីគ្នាទៅវិញទៅមក ក្នុងដំណើរការស្រាវជ្រាវប្រតិបត្តិ ការសិក្សាស្រាវជ្រាវមេរៀន និងស្វ័យឆ្លុះបញ្ចាំងលើការប្រតិបត្តិ ដើម្បីធ្វើឱ្យប្រសើរដល់ទឹកចិត្តក្នុងការបំពេញការងារ លទ្ធផលការងារ និងដល់លទ្ធផលសិក្សារបស់សិស្ស ដែលពួកគេកំពុងបង្រៀន។ សហគមន៍សិក្សាវិជ្ជាជីវៈ គឺជាសហគមន៍ដែលផ្តល់ការគាំទ្រចាំបាច់សម្រាប់គ្រូបង្រៀននៅគ្រឹះស្ថានសិក្សា ដើម្បីឱ្យគ្រូបង្រៀនចេះរួបរួមគ្នាក្នុងការកំណត់សកម្មភាព និងអភិវឌ្ឍសមត្ថភាពរបស់ពួកគេជាប្រចាំ។

### ២.២. បញ្ញត្តិទូទៅនៃសហគមន៍សិក្សាវិជ្ជាជីវៈ

ការបង្កើត និងដំណើរការសហគមន៍សិក្សាវិជ្ជាជីវៈ ត្រូវឈរលើគោលការណ៍សំខាន់ៗ៣គឺ វប្បធម៌សហការ ការផ្តោតលើលទ្ធផលសិក្សារបស់សិស្ស និងការពិភាក្សាឆ្លុះបញ្ចាំង ។

- **វប្បធម៌សហការ៖** សំដៅលើវប្បធម៌មួយដែលមានការទុកចិត្តគ្នា និងពឹងផ្អែកគ្នាទៅវិញទៅមករវាងគ្រប់សមាជិកទាំងអស់នៅក្នុងសហគមន៍ ដើម្បីផ្តល់ឱកាស អំណាច និងសិទ្ធិសេរីភាពទៅគ្រូបង្រៀនដើម្បីធ្វើការសិក្សា និងរៀបចំផែនការរួមគ្នា ហើយជជែកដេញដោលគ្នាទៅវិញទៅមក អំពីការអនុវត្តការងារ ចំណេះដឹង និងផ្តត់គំនិតដែលទាក់ទងនឹងការងារបង្រៀន។ អ្វីដែលសំខាន់ដើម្បីសហការគ្នាបាន គឺត្រូវ

ជានាថាពល់ជម្លោះផ្ទៃក្នុងអាចគ្រប់គ្រងបាន ហើយត្រូវមានផ្នត់គំនិតមួយថា ការសហការ និងជជែកដេញដោលគ្នា ជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍសមត្ថភាពដែលខ្វះខាត។

- **ការផ្តោតលើលទ្ធផលសិក្សារបស់សិស្ស៖** គោលបំណង និងសកម្មភាពរបស់សហគមន៍សិក្សាវិជ្ជាជីវៈត្រូវតែផ្តោតលើការរីកចម្រើន និងការអភិវឌ្ឍរបស់សិស្សជាចម្បង។ ពេលដែលនិយាយពីការអភិវឌ្ឍសាលារៀន គឺសំដៅលើលទ្ធផលសិក្សារបស់សិស្ស។
- **ការពិភាក្សាឆ្លុះបញ្ចាំង៖** សំដៅទៅលើការសន្ទនាដែលផ្តោតលើវិធីសាស្ត្របង្រៀនរបស់គ្រូ និងលទ្ធផលសិក្សារបស់សិស្ស។ ការពិភាក្សានេះ លើកទឹកចិត្តគ្រូបង្រៀនឱ្យពិភាក្សាទៅលើការបង្រៀនរបស់ពួកគាត់ និងឱ្យពួកគាត់សហការគ្នារិះរកវិធីសាស្ត្រដែលអាចធ្វើឱ្យការបង្រៀនមានភាពរីកចម្រើនបន្ថែមបាន។ គ្រូបង្រៀនអាចបង្កើតការសន្ទនាបែបស៊ីជម្រៅ និងសម្រេចចិត្តលើរឿងមួយចំនួនដូចជា កម្មវិធីសិក្សា ការបង្រៀន និងការរៀន ហើយត្រូវឆ្លុះបញ្ចាំងលើសំណួរគន្លឹះសំខាន់ៗ៣ដែលទាក់ទងនឹងការរៀនរបស់សិស្សគឺ ១). តើយើងចង់ឱ្យសិស្សរៀនអ្វី? ២). តើយើងធ្វើយ៉ាងណាទើបដឹងថាសិស្សបានរៀនចេះនូវអ្វីដែលយើងចង់ឱ្យពួកគាត់រៀន និងអ្វីដែលជាបញ្ហាប្រឈមក្នុងការរៀនសូត្ររបស់គាត់? និង៣). តើយើងនឹងធ្វើអ្វីវិញ ប្រសិនបើសិស្សមិនបានរៀនចេះ នូវអ្វីដែលយើងចង់ឱ្យពួកគាត់រៀននោះ?

## ៣. ដំណើរការសហគមន៍សិក្សាវិជ្ជាជីវៈ

### ៣.១. សំណួរតម្រង់ទិសសម្រាប់ដំណើរការសហគមន៍សិក្សាវិជ្ជាជីវៈ

ដើម្បីអាចដំណើរការសហគមន៍សិក្សាវិជ្ជាជីវៈមួយបាន គ្រឹះស្ថានសិក្សាអាចពិចារណាលើសំណួរគន្លឹះចំនួន៦ សម្រាប់តម្រង់ទិសក្នុងការដំណើរការ។ ខាងក្រោមនេះជាតារាងសង្ខេបអំពីដំណើរការខ្លះៗ ដែលអាចទៅរួច ក្នុងការរៀបចំអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈមួយ។

| ១<br>**កំណត់ស្ថានភាពសិស្សបច្ចុប្បន្ន** | ២<br>**កំណត់ចក្ខុវិស័យ** | ៣<br>**រៀបចំរចនាសម្ព័ន្ធ** |
|---|---|---|
| **សំណួរគន្លឹះ**<br>១. តើទិន្នន័យលទ្ធផលសិក្សារបស់សិស្សដែលទទួលបានប្រាប់យើងអ្វីខ្លះពីការរីកចម្រើននៃការសិក្សារបស់សិស្សនៅសាលាយើង?<br>២. តើការអនុវត្តការងារបង្រៀនរបស់ពួកយើងសព្វថ្ងៃមានប្រសិទ្ធភាពកម្រិតណា? | **សំណួរគន្លឹះ**<br>១. តើពួកយើងនឹងបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនេះក្នុងគោលបំណងអ្វី?<br>២. ក្នុងនាមជាសាលារៀនមួយ តើពួកយើងត្រូវប្រកាន់ខ្ជាប់នូវគុណតម្លៃ ការអនុវត្ត និងវប្បធម៌អ្វីខ្លះ? | **សំណួរគន្លឹះ**<br>១. តើពួកយើងអាចរៀបចំរចនាសម្ព័ន្ធសហគមន៍សិក្សាវិជ្ជាជីវៈរបស់ពួកយើងដោយរបៀបណា ដើម្បីឱ្យការបង្រៀនរបស់គ្រូ និងការសិក្សារបស់សិស្សបានល្អ?<br>២. តើពួកយើងនឹងផ្តល់អាទិភាពលើពេលវេលាយ៉ាងដូចម្តេចដើម្បីឱ្យគ្រូអាចមកជួបជុំគ្នាបាន? |
| **យុទ្ធសាស្ត្រ**<br>- ប្រើទិន្នន័យលទ្ធផលសិក្សារបស់សិស្សដើម្បីភាគរកចំនួនសិស្សខ្សោយ និងមូលហេតុដែលនាំឱ្យសិស្សទទួលបានលទ្ធផលខ្សោយ។<br>- អភិវឌ្ឍផែនការគោលសម្រាប់ការងារនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ។ | **យុទ្ធសាស្ត្រ**<br>- សហការគ្នាបង្កើតចក្ខុវិស័យរួមមួយដើម្បីបង្កើតឱ្យមានវប្បធម៌នៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈរបស់ខ្លួនដោយមានការចូលរួមពីគណៈគ្រប់គ្រងសាលារៀន នាយកសាលាប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន។ | **យុទ្ធសាស្ត្រ**<br>- រៀបចំចាត់ចែងឱ្យមានប្រធាននិងអ្នកសម្របសម្រួលដោយសិក្សាពីសមត្ថភាព ស្នាដៃ និងឆន្ទៈរបស់បុគ្គលិកដែលមានស្រាប់។ ករណីខ្វះ ត្រូវគិតពិចារណាក្នុងការស្វែងរក ជំនួយពីប្រភពខាងក្រៅ។ |

| | | |
|---|---|---|
| - កំណត់ឱ្យបានថា ប្រសិនបើបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនេះឡើង តើក្រុមការងាររបស់សាលា នឹងប្រតិបត្តិយ៉ាងដូចម្ដេចដើម្បីឱ្យទទួលលទ្ធផលល្អជាងស្ថានភាពបច្ចុប្បន្ន។ | - បង្កើតផែនការដោយកំណត់យកជំហានផ្សេងៗដើម្បីសម្រេចចក្ខុវិស័យរួម។<br>- ផ្សព្វផ្សាយចក្ខុវិស័យទៅភាគីពាក់ព័ន្ធឱ្យបានទូលំទូលាយ ដើម្បីទាក់ទាញការសហការចូលរួម។ | - ត្រឡប់ទៅមើលកាលវិភាគប្រជុំបច្ចេកទេសដែលមានស្រាប់ រួចសម្រេចជុំគ្នាថានឹងជួបគ្នានៅពេលណាខ្លះក្នុងខែនីមួយៗ។<br>- ផ្សព្វផ្សាយកាលវិភាគជួបជុំរបស់សហគមន៍សិក្សាវិជ្ជាជីវៈទៅសមាជិកក្នុងសហគមន៍ទាំងមូល។ |
| **៤**<br>**កសាងទំនុកចិត្ត** | **៥**<br>**ផ្ដល់សិទ្ធិនិងអំណាចដល់គ្រូ** | **៦**<br>**តាមដាននិងវាយតម្លៃលទ្ធផល** |
| **សំណួរគន្លឹះ**<br>១. តើពួកយើងនឹងអាចកសាងទំនុកចិត្តបានដោយរបៀបណានៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈរបស់ពួកយើង ?<br>២. តើពួកយើងអាចកសាងឆន្ទៈក្នុងការចូលរួមក្នុងដំណើរការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈដោយរបៀបណា ? | **សំណួរគន្លឹះ**<br>១. តើពួកយើងនឹងផ្ដល់សិទ្ធិអំណាចដល់គ្រូបង្រៀនទាំងអស់នៅក្នុងសហគមន៍ពួកយើងយ៉ាងដូចម្ដេច ?<br>២. តើពួកយើងនឹងអាចធានាបានការចូលរួមរបស់ពួកគាត់យ៉ាងដូចម្ដេច ? | **សំណួរគន្លឹះ**<br>១. តើពួកយើងនឹងតាមដានលទ្ធផលសម្រេចការងាររបស់សហគមន៍សិក្សាវិជ្ជាជីវៈ ពិសេសទាក់ទងនឹងការរីកចម្រើនការសិក្សារបស់សិស្សបានយ៉ាងដូចម្ដេច ?<br>២. ប្រសិនបើការងាររបស់សហគមន៍សិក្សាវិជ្ជាជីវៈមិនអាចសម្រេចបានដូចអ្វីដែលរំពឹងទុក តើយើងនឹងជួយគាំទ្រការងារគ្រូបង្រៀនបានយ៉ាងដូចម្ដេច ? |
| **យុទ្ធសាស្ត្រ**<br>- ស្ទង់មតិបុគ្គលិកទាក់ទងនឹងទស្សនៈយល់ឃើញចំពោះទំនាក់ទំនងរបស់ពួកគេជាមួយក្រុមការងារ។<br>- បើកទូលាយឱ្យមានការចែករំលែកភាពបរាជ័យ បញ្ហាប្រឈម ក៏ដូចជាភាពជោគជ័យក្នុងការទំនាក់ទំនងការងារប្រចាំថ្ងៃ។<br>- បង្ហាញគុណតម្លៃរបស់សហគមន៍សិក្សាវិជ្ជាជីវៈទៅគ្រូបង្រៀនតាមរយៈការលើកយកករណីសាលាផ្សេងៗមកធ្វើជាករណីសិក្សា និងណែនាំអំពីការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំ និងពីគន្លងអាជីពគ្រូបង្រៀនទៅថ្ងៃខាងមុខ។ | **យុទ្ធសាស្ត្រ**<br>- ត្រួតពិនិត្យមើលសមត្ថភាព និងភាពជំនាញរបស់បុគ្គលិកដើម្បីបង្កើតវិធីសាស្ត្រដោះស្រាយ និងពង្រឹងសមត្ថភាព។<br>- ក្រៅពីបុគ្គលិកលក្ខណៈនៃភាពល្អភាពធ្មើម និងភាពឈានមុខ ត្រូវវាយតម្លៃលើឆន្ទៈរបស់អ្នកសម្របសម្រួលជាពិសេស ពីព្រោះអ្នកសម្របសម្រួលជាកត្តាសំខាន់ក្នុងការជំរុញឱ្យអ្នកផ្សេងចូលរួម។<br>- ពន្យល់ណែនាំពីសារប្រយោជន៍នៃការចូលរួមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈទៅនឹងការវាយតម្លៃតាមប្រព័ន្ធក្រេឌីតនៃនិងណែនាំអំពីការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពគ្រូបង្រៀន។ | **យុទ្ធសាស្ត្រ**<br>- ដឹកនាំការប្រជុំឱ្យទៀងទាត់ជាមួយប្រធានសហគមន៍ ដើម្បីពិភាក្សាលើវឌ្ឍនភាពដោយប្រើទិន្នន័យសិក្សារបស់សិស្សមកវិភាគ។<br>- ប្រមូលទិន្នន័យលទ្ធផលសិក្សានិងមតិយោបល់ត្រឡប់របស់សិស្សដើម្បីកំណត់បានថាការអនុវត្តការងារកន្លងមកមានភាពជោគជ័យឬអត់។<br>- លើកយកចក្ខុវិស័យរបស់សហគមន៍មករំលឹកឡើងវិញដើម្បីឱ្យអ្នកទទួលខុសត្រូវមានការភ្ញាក់រលឹកនិងបំពេញភារកិច្ច។<br>- ប្រឹក្សាយោបល់គ្នារវាងគ្រូបង្រៀនសិស្ស និងអាណាព្យាបាលសិស្សដើម្បីវាស់ស្ទង់ពីឥទ្ធិពលរបស់សហគមន៍សិក្សាវិជ្ជាជីវៈ។ |

## ៣.២. វដ្តនៃការចោទសួរនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ

ការផ្តោតលើការអនុវត្តការបង្រៀនរបស់គ្រូ មានសារៈសំខាន់នៅក្នុងដំណើរការរបស់សហគមន៍សិក្សាវិជ្ជាជីវៈ។ ការអនុវត្តការបង្រៀននេះ ពឹងផ្អែកលើការសហការការរិះរកពីប្រសិទ្ធភាពនៃការអនុវត្តការងាររបស់សមាជិក ប្រធាន និង អ្នកសម្របសម្រួលទាំងអស់នៅក្នុងសហគមន៍។ វដ្តនៃការចោទសួរ (Inquiry Cycle) អាចប្រើការបាន ដើម្បីស្វែងរកពីប្រសិទ្ធភាពក្នុងការអនុវត្តការងាររបស់សហគមន៍សិក្សាវិជ្ជាជីវៈបានតាមរយៈ៥ ជំហានដូចខាងក្រោម៖

- **កំណត់បញ្ហា៖** គ្រូបង្រៀនត្រូវកំណត់ឱ្យបានថាអ្វីជាបញ្ហាពិតប្រាកដទាក់ទងនឹងលទ្ធផលសិក្សារបស់សិស្ស ដោយធ្វើការឆ្លុះបញ្ចាំងលើការអនុវត្តការបង្រៀនសព្វថ្ងៃ ហើយរើសយកតែបញ្ហាប្រឈមមួយឬពីរមកពិភាក្សារួមគ្នាគឺអាចនឹងគ្រប់គ្រាន់ល្មមហើយ។ ដូច្នេះសំណួរ ដែលសហគមន៍ត្រូវចោទសួរបានគឺសួរថា *"តើអ្វីជាបញ្ហាដែលកំពុងកើតឡើង?"*
- **វិភាគបញ្ហា៖** គ្រូបង្រៀនត្រូវវិភាគរួមគ្នា និងជជែកដេញដោលដើម្បីស្វែងរកឱ្យឃើញនូវប្រភពនៃបញ្ហាដែលកំពុងកើតឡើង តាមរយៈការសួរថា *"ហេតុអ្វីបានជាបញ្ហាហ្នឹងកើតឡើង?"*
- **ធ្វើផែនការ៖** បន្ទាប់ពីរកមូលហេតុនៃបញ្ហា ដែលគ្រូបង្រៀនជួបប្រទះរួចហើយ ពួកគាត់ត្រូវគិតបន្តទៀតពីសកម្មភាពដែលអាចធ្វើទៅរួចដើម្បីបង្កើតជាដំណោះស្រាយ។ ដូច្នេះ ត្រូវសួរបន្តទៀតថា *"តើយើងនឹងធ្វើអ្វី បន្ទាប់ពីដឹងមូលហេតុរួចហើយ?"* នៅក្នុងចំណុចនេះ គ្រូបង្រៀននឹងលើកជាសកម្មភាពផ្សេងៗដែលពួកគាត់នឹងធ្វើដើម្បីបង្កើតជាដំណោះស្រាយ។
- **អនុវត្តផែនការ៖** សកម្មភាពដែលបានកំណត់ នឹងត្រូវយកទៅអនុវត្តនៅកម្រិតថ្នាក់រៀន។
- **វាយតម្លៃ៖** ចុងក្រោយត្រូវធ្វើការវាយតម្លៃពីប្រសិទ្ធភាពនៃការអនុវត្តកន្លងមក ដោយត្រូវចោទសួរថា *"តើអ្វីដែលយើងអនុវត្តកន្លងមកមានដំណើរការឬទេ?"*

ការប្រតិបត្តិការងារនឹងវិលចូលវដ្តថ្មីមួយទៀត បន្ទាប់ពីជំហានទី៥បានបញ្ចប់ និងនៅពេលដែលមានការឯកភាពពីសមាជិកសហគមន៍ថាបានដោះស្រាយបញ្ហាដែលបានកំណត់ប្រកបដោយជោគជ័យ។ បន្ទាប់មកត្រូវកំណត់បញ្ហាថ្មីៗ ដើម្បីដោះស្រាយបន្តទៀតនៅក្នុងវដ្តបន្តបន្ទាប់។



### ៣.៣. សកម្មភាពពាសំខាន់ៗដែលអាចអនុវត្តបាននៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ

មានសកម្មភាពពាសំខាន់ៗ ដែលសហគមន៍សិក្សាវិជ្ជាជីវៈមួយអាចធ្វើការរួមគ្នាបានគឺៈ ការស្រាវជ្រាវប្រតិបត្តិ ការសិក្សាស្រាវជ្រាវមេរៀន និងការឆ្លុះបញ្ចាំងលើការប្រតិបត្តិ ដែលរួមបញ្ចូលការចែករំលែកបទពិសោធន៍ដឹកនាំ ឯកសារ សម្ភារៈ និងវិធីសាស្ត្របង្រៀនផ្សេងៗ។

**ក. ការស្រាវជ្រាវប្រតិបត្តិ ( Action Research )**

- **តើអ្វីជាការស្រាវជ្រាវប្រតិបត្តិ ?**

  ការស្រាវជ្រាវប្រតិបត្តិជាដំណើរការមួយដែលគ្រូបង្រៀនឬអ្នកអប់រំធ្វើការឆ្លុះបញ្ចាំង ដើម្បីសម្រេចចិត្តលើការងារបង្រៀននិងបំពេញតម្រូវការសិស្សរបស់ខ្លួន តាមរយៈទិន្នន័យដែលប្រមូលបានពីថ្នាក់រៀន។ ពេលដែលធ្វើការស្រាវជ្រាវប្រតិបត្តិ គ្រូបង្រៀនអាចប្រមូលទិន្នន័យពីថ្នាក់រៀនខ្លួនឯងផ្ទាល់។ ទិន្នន័យដែលបានមក អាចធ្វើឱ្យគ្រូឆ្លុះបញ្ចាំងការអនុវត្តជាក់ស្តែងរបស់ថ្នាក់រៀនគាត់។

- **តើត្រូវអនុវត្តការស្រាវជ្រាវប្រតិបត្តិយ៉ាងដូចម្តេច ?**

  មាន៤ដំណាក់កាលធំៗ ដែលអាចឱ្យគ្រូបង្រៀនធ្វើការស្រាវជ្រាវប្រតិបត្តិលើថ្នាក់រៀនរបស់គាត់បានៈ

  ១. កំណត់រកឱ្យឃើញបញ្ហាណាមួយក្នុងថ្នាក់រៀន

  ២. កសាង និងដាក់ចេញនូវផែនការស្រាវជ្រាវប្រតិបត្តិ

  ៣. ប្រមូល និងវិភាគទិន្នន័យ

  ៤. ប្រើប្រាស់ និងចែករំលែកលទ្ធផលសិក្សាស្រាវជ្រាវ

  បន្ទាប់ពីបានលទ្ធផលរួចហើយ អ្វីដែលគ្រូបង្រៀនត្រូវធ្វើនៅដំណាក់កាលបញ្ចប់គឺធ្វើការសម្រេចចិត្តថានឹងត្រូវចាត់វិធានការអ្វី ដើម្បីធានាបានថាលទ្ធផលសិក្សារបស់សិស្សមានការកើនឡើងជាបន្តបន្ទាប់។




ក្នុងដំណើរការស្រាវជ្រាវប្រតិបត្តិ គ្រូបង្រៀនអាចរើសយកការសិក្សាដោយផ្តោតលើលក្ខណៈសិស្សតែម្នាក់ សិស្សមួយក្រុម ថ្នាក់រៀនមួយឬច្រើន ឬក៏សាលារៀនទាំងមូល។ ទោះក្នុងកម្រិតណាក៏ដោយ ការស្រាវជ្រាវប្រតិបត្តិ អាស្រ័យលើការចាប់អារម្មណ៍ តម្រូវការ និងកម្រិតនៃការគាំទ្រពីសាលារៀននិងគ្រូបង្រៀនជាសំខាន់។ ជាទូទៅ ការស្រាវជ្រាវប្រតិបត្តិ អាចធ្វើឡើងជា ទម្រង់ស្រាវជ្រាវលក្ខណៈបុគ្គល ទម្រង់ស្រាវជ្រាវលក្ខណៈសហការ និងទម្រង់ស្រាវជ្រាវលក្ខណៈកម្រិតសាលា។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យអនុវត្តសៀវភៅបច្ចេកទេសគន្លឹះនៃការស្រាវជ្រាវប្រតិបត្តិនៅឆ្នាំ២០២០ ដែលសហគមន៍សិក្សាវិជ្ជាជីវៈអាចប្រើប្រាស់បាន។

## ខ. ការសិក្សាស្រាវជ្រាវមេរៀន (Lesson Study)

ការសិក្សាស្រាវជ្រាវមេរៀន មានដើមកំណើតនៅប្រទេសសជប៉ុន ហើយត្រូវបានយកមកអនុវត្តក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ២០០៦ ដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) តាមរយៈគម្រោង STEPSAM2។

- **តើអ្វីជាការសិក្សាស្រាវជ្រាវមេរៀន?**

ការសិក្សាស្រាវជ្រាវមេរៀនគឺជាដំណើរការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ដែលក្រុមគ្រូបង្រៀន មានមុខវិជ្ជាដូចគ្នា ឬកម្រិតថ្នាក់ដូចគ្នា ត្រូវចូលរួម វិភាគលើមេរៀនតាមរយៈការជួយធ្វើកិច្ចតែងការបង្រៀន ជួយផ្តល់វិធីសាស្ត្របង្រៀន និងជួយផលិតសម្ភារៈបង្រៀន។

- **តើត្រូវអនុវត្តការសិក្សាស្រាវជ្រាវមេរៀនយ៉ាងដូចម្តេច?**

ជាទូទៅដើម្បីផលិតបានកិច្ចតែងការបង្រៀនមួយ ឬអនុវត្តចប់មួយវដ្តនៃការសិក្សាស្រាវជ្រាវមេរៀន ក្រុមគ្រូបង្រៀនត្រូវអនុវត្ត ៤ដំណាក់កាលដូចខាងក្រោម៖

- **ការរៀបចំមេរៀន៖** ការរៀបចំនេះ មាន៤ជំហាន។ ជំហានទី១). ត្រូវពិភាក្សាគ្នា ដើម្បីចាត់តាំងគ្រូបង្រៀនដែលត្រូវឡើងបង្រៀន ដោយត្រូវកំណត់ថ្ងៃជួបជុំគ្នា ថ្ងៃឡើងបង្រៀន និងប្រធានបទបង្រៀន។ ជំហានទី២). គ្រូបង្រៀន ដែលត្រូវបានចាត់តាំង ធ្វើការសិក្សាអំពីខ្លឹមសារមេរៀន និងរៀបចំកិច្ចតែងការបង្រៀន។ ជំហានទី៣). ក្រុមសិក្សាស្រាវជ្រាវមេរៀន ពិនិត្យមើល និងពិភាក្សាកិច្ចតែងការបង្រៀននោះ។ ជំហានទី៤). ផ្អែកលើអនុសាសន៍ ដែលបានផ្តល់ជូន គ្រូបង្រៀនដែលត្រូវបានចាត់តាំង អាចកែលម្អកិច្ចតែងការបង្រៀននោះតាមការជាក់ស្តែង។
- **ការអនុវត្តការបង្រៀន និងការសង្កេត៖** បន្ទាប់ពីបានកិច្ចតែងការបង្រៀនសម្រេចចុងក្រោយហើយ សមាជិកក្រុមសិក្សាស្រាវជ្រាវមេរៀន ចុះសង្កេតការបង្រៀនរបស់គ្រូដែលបានចាត់តាំងនោះ ដោយសង្កេតអំពីវិធីបង្រៀនរបស់គ្រូ និងរបៀបរៀនរបស់សិស្ស (អ្វីដែលសិស្សបានរៀន និងមិនបានរៀនក្នុងម៉ោងបង្រៀននោះ)។ នៅពេលចុះសង្កេត គ្រូសង្កេត ត្រូវមានឧបករណ៍សង្កេតដើម្បីកត់ត្រាសកម្មភាពបង្រៀនរបស់គ្រូ និងសកម្មភាពរៀនរបស់សិស្ស។
- **ការពិភាក្សាលើការបង្រៀន និងរៀន៖** បន្ទាប់ពីចប់ការបង្រៀន និងសង្កេតរួចមក នឹងមានការពិភាក្សាមួយ ដើម្បីកែលម្អការបង្រៀន និងផ្តល់ឱកាសដល់សមាជិកក្រុមសិក្សាស្រាវជ្រាវមេរៀនផ្សេងៗទៀត បានស្វែងយល់ និងផ្លាស់ប្តូរបទពិសោធន៍។ ការពិភាក្សានេះ ត្រូវឈរលើគោលការណ៍ជាក់លាក់មួយ ដែលកំណត់ដោយសមាជិកក្រុមទាំងអស់ និងត្រូវមានឧបករណ៍ពិភាក្សាដើម្បីកត់ត្រាការអនុវត្ត។
- **ការធ្វើសកម្មភាពកែលម្អបន្ត៖** នៅក្នុងដំណាក់កាលនេះ សមាជិកក្រុមសិក្សាស្រាវជ្រាវមេរៀន ត្រូវបានលើកទឹកចិត្តឱ្យកែលម្អការងាររបស់ខ្លួនបន្ត ពីព្រោះ ការអភិវឌ្ឍ គឺគ្មានទីបញ្ចប់ទេ។ ដូច្នេះ គ្រូបង្រៀនអាចបើកកិច្ចប្រជុំ ដើម្បីជ្រើសរើសគ្រូដែលត្រូវបង្រៀនបន្ត និងណែនាំឱ្យគាត់រៀបចំមេរៀនបង្រៀន។

ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ឱ្យអនុវត្តសៀវភៅណែនាំស្តីពីការសិក្សាស្រាវជ្រាវមេរៀន នៅឆ្នាំ ២០១១ ដែលសហគមន៍សិក្សាវិជ្ជាជីវៈ អាចប្រើប្រាស់បាន។

## គ. ស្វ័យឆ្លុះបញ្ចាំងលើការប្រតិបត្តិ ( Reflective Practice )

ការឆ្លុះបញ្ចាំងជាផ្នែកមួយនៃការបង្រៀននិងរៀន ដែលមានបំណងឱ្យគ្រូបង្រៀនភ្ញាក់រឭកពីចំណេះដឹង និងការអនុវត្តវិជ្ជាជីវៈរបស់ខ្លួន តាមរយៈការយកចម្ងល់ទាំងឡាយដែលទាក់ទងនឹងការអនុវត្តការងារមកស្រាយបំភ្លឺ ហើយធ្វើការវាយតម្លៃប្រកបដោយការពិចារណានិងស៊ីជម្រៅ។ តាមរយៈការឆ្លុះបញ្ចាំងលើការបង្រៀនរបស់ខ្លួន គ្រូបង្រៀនអាចកំណត់បានថាអ្វីជាឧបសគ្គក្នុងការរៀនរបស់សិស្ស។ គ្រូដែលធ្វើការឆ្លុះបញ្ចាំងនឹងអាចរិះរកវិធីថ្មីៗដើម្បីដោះស្រាយបញ្ហាប្រឈមនៅក្នុងកម្រិតថ្នាក់គាត់។ បន្ថែមពីនេះ ការដែលគ្រូម្នាក់ធ្វើការឆ្លុះបញ្ចាំង និងស្វែងរកវិធីសាស្ត្រដោះស្រាយបញ្ហាដែលទាក់ទងនឹងការបង្រៀនចំពោះមុខ វាបង្ហាញពីទំនួលខុសត្រូវរបស់គ្រូ និងជាសញ្ញាមួយប្រាប់ថាគ្រូបង្រៀននោះមានគំនិតច្នៃប្រឌិតក្នុងការដោះស្រាយបញ្ហា ដែលវានឹងបង្កើនទំនុកចិត្តទាំងគ្រូនិងសិស្សក្នុងការងារបង្រៀននិងរៀន។

- **តើអ្វីជាស្វ័យឆ្លុះបញ្ចាំងលើការប្រតិបត្តិ?**

  ស្វ័យឆ្លុះបញ្ចាំងលើការប្រតិបត្តិជាដំណើរការឆ្លុះបញ្ចាំងដដែលៗមួយ ដែលក្នុងនោះគ្រូបង្រៀនអាចរៀនបានពីបទពិសោធន៍ និងរៀនតាមរយៈបទពិសោធន៍ ដើម្បីទទួលបានគំនិតថ្មីៗសម្រាប់ការអនុវត្តការងារបង្រៀនតាមរយៈការគិតពិចារណារបស់គ្រូបង្រៀនជាមួយអ្នកដទៃ ដើម្បីចែករំលែកឧត្តមានុវត្ត ហើយយកឧត្តមានុវត្តទាំងនោះមកគាំទ្រការអនុវត្តការងារបង្រៀនរបស់ខ្លួន។

- **តើត្រូវអនុវត្តស្វ័យឆ្លុះបញ្ចាំងលើការប្រតិបត្តិយ៉ាងដូចម្តេច?**

  ការឆ្លុះបញ្ចាំងលើការប្រតិបត្តិជាដំណើរការមួយ ដែលគ្រូបង្រៀនត្រូវអនុវត្តជាវដ្ត ពោលគឺគ្រូបង្រៀនត្រូវធ្វើការឆ្លុះបញ្ចាំងម្តងហើយម្តងទៀត ដើម្បីបង្កើតជាដំណោះស្រាយរួម។ ក្នុងដំណើរការនោះ មានដំណាក់កាលសំខាន់ៗចំនួន៤គឺ៖ ១).បង្រៀន ២).វាស់ស្ទង់លទ្ធផលឬសមត្ថភាពបង្រៀនរបស់ខ្លួន ៣).ពិចារណាវិធីថ្មីៗនៃការបង្រៀន ដែលអាចធានាបាននូវការរីកចម្រើនរបស់សិស្ស ៤).សាកល្បងអនុវត្តគំនិតថ្មីៗដែលទទួលបានពីខ្លួនឯងឬអ្នកដទៃ និងចុងក្រោយគឺធ្វើវាម្តងទៀត។



## ៤. សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គណៈគ្រប់គ្រង

### ៤.១. សមាសភាព

សមាសភាពរបស់សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គណៈគ្រប់គ្រង សំដៅដល់នាយក នាយករង គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងសាលារៀនចំណេះទូទៅដែលស្ថិតនៅជិតគ្នា ឬស្ថិតនៅក្នុងក្រុង ស្រុក ខណ្ឌ ជាមួយគ្នាដែលមានឆន្ទៈ និងលទ្ធភាពចូលរួមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈជាមួយគ្នា។ ចំនួន និងសមាសភាពរបស់សហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗ អាចប្រែប្រួលតាមទីកន្លែងជាក់ស្តែង ដោយបើកទូលាយឱ្យអ្នកជំនាញមកពីអង្គភាពផ្សេងៗ អាចចូលរួមបានផងដែរដូចជា មកពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត សហគមន៍សិក្សាទាក់ទងនឹងការងារអប់រំ អ្នកដឹកនាំអង្គការ ឬអង្គភាពឯកជនជាដើម។ សហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗ ត្រូវមានប្រធានម្នាក់ និងអ្នកសម្របសម្រួលម្នាក់ ដែលត្រូវបានជ្រើសរើសក្នុងចំណោមសមាសភាពនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗ។ ប្រធានក្រុម និងអ្នកសម្របសម្រួល គឺជាអ្នកមានបទពិសោធន៍ដឹកនាំទទួលបានជោគជ័យ មានបច្ចេកទេស កម្រិតវប្បធម៌ និងមានស្មារតីទទួលខុសត្រូវចំពោះសមាជិកសហគមន៍សិក្សាវិជ្ជាជីវៈរបស់ខ្លួន។

បេក្ខភាពប្រធានសហគមន៍នៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងសាលារៀនចំណេះទូទៅ អាចជានាយកល្អ នាយកឈានមុខ ឬនាយកឆ្នើម ដែលទទួលបានពានរង្វាន់ស្នាដៃការងារក្នុងការដឹកនាំអង្គភាពរបស់ខ្លួន។ ចំពោះសាលារៀនចំណេះទូទៅវិញ គណៈអភិបាលស្រុក ក៏អាចជាបេក្ខភាពប្រធានសហគមន៍សិក្សាវិជ្ជាជីវៈផងដែរ។ រីឯការរើសបេក្ខភាពអ្នកសម្របសម្រួលនៅកម្រិតសាលាចំណេះទូទៅវិញ អាចធ្វើឡើងតាមរយៈ២ករណី។ ករណីទី១ អាចធ្វើឡើងដោយរើសយកនាយកណាមួយក្នុងចំណោមនាយក ឬនាយករង ៧ ទៅ ៩នាក់ របស់សាលាជិតគ្នា។ ករណីទី២ ប្រសិនបើសាលារៀនចំណេះទូទៅ រកអ្នកសម្របសម្រួលមិនបាន សាលាអាចស្នើទៅមន្ទីរឬក្រសួងដើម្បីសុំបេក្ខភាពអ្នកសម្របសម្រួល។ ប្រធានក្រុម និងអ្នកសម្របសម្រួល ត្រូវធ្វើការជ្រើសរើស ដោយការតែងតាំង ឬបោះឆ្នោត និងធ្វើការផ្លាស់ប្តូរមុនឆ្នាំសិក្សានីមួយៗ។

ចំពោះកម្រិតសាលាចំណេះទូទៅ ប្រធានសហគមន៍នៅកម្រិតអនុវិទ្យាល័យ ឬវិទ្យាល័យ អាចធ្វើការសហការគ្នាជាមួយប្រធានសហគមន៍នៅកម្រិតបឋមសិក្សាបាន ដើម្បីសហការគ្នា ដូចជាការសម្របសម្រួល និងផ្តល់ការត្រៀមលក្ខណៈការផ្ទេរសិស្សពីកម្រិតបឋមសិក្សាមកកម្រិតអនុវិទ្យាល័យបាន។

### ៤.២. តួនាទី និងភារកិច្ច

សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់នាយកសាលា ត្រូវមានផែនការគោលរួមមួយ ដែលមានកំណត់នូវចក្ខុវិស័យ បេសកកម្មច្បាស់លាស់ និងសកម្មភាពអាទិភាពត្រូវអនុវត្ត ដើម្បីសម្រេចគោលដៅដែលខ្លួនចង់បាន។ សហគមន៍សិក្សានេះ ត្រូវផ្តោតលើការងារគ្រប់គ្រងសាលារៀនដូចជា ការគ្រប់គ្រងទូទៅ ភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងការងារបង្រៀននិងកម្មវិធីសិក្សា ការគ្រប់គ្រងបុគ្គលិក និងការគ្រប់គ្រងហិរញ្ញវត្ថុជាដើម ដើម្បីធ្វើឱ្យអង្គភាពសាលារៀននីមួយៗ មានដំណើរការប្រកបដោយប្រសិទ្ធភាព។ ដូច្នេះ សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់នាយកសាលា ត្រូវមានភារកិច្ចមួយចំនួនដូចជា៖

- សិក្សាស្រាវជ្រាវលើការដឹកនាំ និងគ្រប់គ្រងសាលារៀន
- ចែករំលែកបទពិសោធន៍ និងចំណេះដឹងថ្មីៗលើការដឹកនាំ និងគ្រប់គ្រងសាលារៀន
- រិះរកមធ្យោបាយ និងយុទ្ធសាស្ត្រថ្មីៗក្នុងការដឹកនាំ និងគ្រប់គ្រងសាលារៀន

- ជួយសមាជិកក្នុងការកសាង និងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន
- ជួយសមាជិកឱ្យអនុវត្តបានតាមគន្លងអាជីពគណៈគ្រប់គ្រងសាលា
- វិភាគលទ្ធផលសិក្សារបស់សិស្ស និងរកវិធីកែលម្អលើការបង្រៀន និងរៀន
- អភិវឌ្ឍសមត្ថភាពសមាជិកជាប្រចាំ។

### ៤.៣. របៀបរបបអនុវត្តការងារ

ការសិក្សាត្រូវដឹកនាំដោយប្រធានក្រុម និងអ្នកសម្របសម្រួល។ រាល់ការប្រជុំត្រូវមានលិខិតប្រជុំ អមដោយរបៀបវារៈប្រជុំ ជូនជាព័ត៌មាន ឬជាការអញ្ជើញថ្នាក់ដឹកនាំអប់រំថ្នាក់ស្រុក ឬមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីជួយសម្របសម្រួល និងផ្ដល់នូវមតិយោបល់កែលម្អបន្ថែម។ ចំពោះកាលបរិច្ឆេទនៃការជួបជុំគ្នាត្រូវមានការឯកភាពគ្នារវាងសមាជិកក្នុងសហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗ ហើយត្រូវមានផែនការសិក្សា និងកំណត់ពេលវេលាជាក់លាក់ ដែលសមាជិកទាំងអស់អាចចូលរួមបានទាំងអស់គ្នា។ ការជួបជុំគ្នាគួរធ្វើឡើងចំនួនពីរដងក្នុងមួយខែតាមការជាក់ស្ដែង។

**ឧទាហរណ៍៖** ខែធ្នូ ក្នុងសប្ដាហ៍ទី១ និងទី៣

- ព្រឹកថ្ងៃអង្គារ ពីម៉ោង៧ និង៣០នាទី ដល់ម៉ោង១០ និង៣០នាទី

ឬ ខែធ្នូ ក្នុងសប្ដាហ៍ទី២ និងទី៤

- រសៀលថ្ងៃសៅរ៍ ពីម៉ោង ១ និង៣០នាទី ដល់ម៉ោង៤ និង៣០នាទី

ការប្រជុំ អាចធ្វើឡើងតាមរយៈការប្រជុំផ្ទាល់ ឬតាមប្រព័ន្ធអេឡិចត្រូនិច ដូចជា Zoom ឬ Google Meet ជាដើម។ ចំពោះទីតាំងប្រជុំ អាចកំណត់យកនៅក្នុងសាលារៀនជាក់លាក់ណាមួយ ឬធ្វើការប្ដូរទីកន្លែងពីសាលារៀនមួយទៅសាលារៀនមួយទៀតជាលក្ខណៈវិលជុំ ឬអាចធ្វើនៅទីតាំងក្រៅសាលាដែល ផ្ដល់ផាសុខភាព និងមានភាពងាយស្រួល។ ប្រធានក្រុម និងអ្នកសម្របសម្រួល ត្រូវជម្រាបជូនដល់សមាជិកខ្លួននូវរបៀបវារៈប្រជុំ និងជូនព័ត៌មានទៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ដើម្បីជាព័ត៌មានផង និងជាការអញ្ជើញឱ្យចូលរួមស្ដាប់ ឬផ្ដល់មតិយោបល់ជុំវិញការសិក្សាឱ្យបានមុនមួយសប្ដាហ៍។ ក្នុងករណីមានមេរៀន ឬឯកសារយោងត្រូវផ្ញើជូនដល់សមាជិកខ្លួនសម្រាប់អានមុនពេលចូលរួមប្រជុំផងដែរ។ រាល់ការប្រជុំត្រូវមានរបាយការណ៍ ឬកំណត់ហេតុ ដើម្បីរក្សាទុកជាឯកសារ ឬភស្តុតាង ហើយសមាជិកម្នាក់ៗត្រូវចងក្រងខ្លឹមសារ និងរក្សាទុកក្នុងកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន (School Director Portfolio)។

## ៥. សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូឧទ្ទេស

### ៥.១. សមាសភាព

គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ត្រូវរៀបចំសហគមន៍សិក្សាវិជ្ជាជីវៈ ដោយប្រើប្រាស់ក្រុមបច្ចេកទេសតាមមុខវិជ្ជាឯកទេសដូចគ្នាដែលមានស្រាប់។ សហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗត្រូវមានប្រធានក្រុមម្នាក់ និងអ្នកសម្របសម្រួលម្នាក់ ដែលជ្រើសរើសក្នុងចំណោមសមាសភាពនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗ។ ប្រធានក្រុម និងអ្នកសម្របសម្រួល គឺជាអ្នកមានបទពិសោធន៍ការងារ មានបច្ចេកទេស កម្រិតវប្បធម៌ និងមានស្មារតីទទួលខុសត្រូវចំពោះសមាជិកសហគមន៍សិក្សាវិជ្ជាជីវៈរបស់ខ្លួន។ ក្នុងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ ប្រធានក្រុម និងអ្នកសម្របសម្រួល អាចជា គ្រូឧទ្ទេសល្អ គ្រូឧទ្ទេសឈានមុខ ឬគ្រូឧទ្ទេសឆ្នើម ដែលទទួលបាន

៣នវង្វាន់ស្នាដៃការងារក្នុងការសិក្សាស្រាវជ្រាវ និងការងារបង្រៀននិងរៀន។ បន្ថែមពីនេះ ប្រធានក្រុមក៏អាចជ្រើសរើសយកពីមន្ទីរ គ្រឹះស្ថានឧត្តមសិក្សា និងនាយកដ្ឋានបច្ចេកទេសរបស់ក្រសួង លើកលែងតែអ្នកសម្របសម្រួល គឺត្រូវតែជានាយកគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ។ ប្រធានក្រុម និងអ្នកសម្របសម្រួល ត្រូវធ្វើការជ្រើសរើសដោយការតែងតាំង ឬបោះឆ្នោត និងធ្វើការផ្លាស់ប្តូរមុនឆ្នាំសិក្សានីមួយៗ។ ចំនួន និងសមាសភាពរបស់សហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗ អាចប្រែប្រួលតាមការជាក់ស្តែង។ ករណីមុខវិជ្ជាដែលមានគ្រូឧទ្ទេសតិចជាង០៥នាក់ នាយកអាចចាត់បញ្ចូលគ្នាជាមួយក្រុមបច្ចេកទេសផ្សេងទៀត ដែលជាមុខវិជ្ជាពាក់ព័ន្ធគ្នាតាមការជាក់ស្តែង។

ឧទាហរណ៍៖ - ក្រុមបច្ចេកទេសភូមិវិទ្យា ប្រវត្តិវិទ្យា

- ក្រុមបច្ចេកទេសគីមីវិទ្យា ជីវវិទ្យា

- ក្រុមបច្ចេកទេសគណិតវិទ្យា រូបវិទ្យា

- ក្រុមបច្ចេកទេសភាសាខ្មែរ សីលធម៌-ពលរដ្ឋវិជ្ជា

ករណីគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ មានចំនួនគ្រូឧទ្ទេសតិច នាយកអាចចែកជាពីរក្រុមមុខវិជ្ជាគឺ៖

- ក្រុមមុខវិជ្ជាវិទ្យាសាស្ត្រពិត

- ក្រុមមុខវិជ្ជាវិទ្យាសាស្ត្រសង្គម

## ៥.២. តួនាទី និងភារកិច្ច

សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូឧទ្ទេស ត្រូវមានផែនការគោលរួមមួយ ដោយមានកំណត់នូវចក្ខុវិស័យ បេសកកម្មច្បាស់លាស់ និងសកម្មភាពអាទិភាព ដើម្បីសម្រេចគោលដៅដែលខ្លួនចង់បាន។ សហគមន៍នេះ ត្រូវផ្តោតលើការងារស្រាវជ្រាវប្រតិបត្តិ ការស្រាវជ្រាវគរុកោសល្យ ការស្រាវជ្រាវលើខ្លឹមសារមុខវិជ្ជាឯកទេស ការងារបង្រៀននិងរៀន ការអភិវឌ្ឍកម្មវិធីសិក្សា ការងារគ្រប់គ្រងថ្នាក់រៀន និងការវិភាគលទ្ធផលសិក្សារបស់សិស្សជាដើម ដើម្បីធ្វើឱ្យគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនដំណើរការប្រកបដោយប្រសិទ្ធភាព។ ដូច្នេះ សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូឧទ្ទេសនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ត្រូវមានភារកិច្ចដូចជា៖

- សិក្សាស្រាវជ្រាវឯកសារ សៀវភៅទាក់ទងការបង្រៀន និងរៀន
- ធ្វើការស្រាវជ្រាវប្រតិបត្តិ ដើម្បីកែលម្អការងារបង្រៀន និងរៀន
- អនុវត្តការសិក្សាស្រាវជ្រាវមេរៀន និងធ្វើថ្នាក់និទស្សន៍ ដើម្បីផ្លាស់ប្តូរបទពិសោធន៍
- ចាត់តាំងសមាជិកឱ្យចូលស្តាប់ការបង្រៀន និងការអប់រំគរុសិស្សរបស់គ្រូឧទ្ទេសណាម្នាក់ ហើយផ្លាស់ប្តូរយោបល់ និងដកបទពិសោធ
- ចងក្រងឯកសារវិធីបង្រៀន និងយុទ្ធសាស្ត្រថ្មីៗសម្រាប់ការងារបង្រៀន និងរៀន ឱ្យមានប្រសិទ្ធភាព
- ចែករំលែកបទពិសោធន៍ការស្រាវជ្រាវ ឬប្រសិទ្ធភាពនៃការងារបង្រៀន និងរៀនដល់សមាជិក
- ធ្វើបទបង្ហាញចំណេះដឹងដែលសមាជិកទទួលបានតាមរយៈការចូលរួមវគ្គបំប៉ន ឬសិក្ខាសាលា
- ដឹកនាំថតជាវីដេអូការបង្រៀនដោយប្រើវិធីបង្រៀនថ្មីៗ សម្រាប់ចែករំលែកដល់សាលារៀនដទៃ
- ជួយសមាជិករៀបចំផែនការអភិវឌ្ឍន៍វិជ្ជាជីវៈប្រចាំឆ្នាំ ព្រមទាំងតាមដាននូវការអនុវត្ត ដើម្បីធ្វើឱ្យ សម្រេចបាននូវស្តង់ដាវិជ្ជាជីវៈ
- ធ្វើការវិភាគលើលទ្ធផលសិក្សារបស់សិស្ស និងរកវិធីកែលម្អលទ្ធផលសិក្សារបស់គរុសិស្ស និស្សិត

- ជួយបំប៉ន និងលើកកម្ពស់កម្រិតវប្បធម៌ បច្ចេកទេសដល់សមាជិករបស់ខ្លួន។

## ៥.៣. របៀបរបបអនុវត្តការងារ

### ក. ការសិក្សាជាក្រុម

ការប្រជុំត្រូវដឹកនាំសម្របសម្រួលដោយប្រធានក្រុម និងអ្នកសម្របសម្រួល។ រាល់ការប្រជុំត្រូវមានលិខិតប្រជុំអមដោយរបៀបវារៈប្រជុំ ជូនជាព័ត៌មាន ឬជាការអញ្ជើញគណៈគ្រប់គ្រងអង្គភាព និងនាយករងបច្ចេកទេស ដើម្បីជួយសម្របសម្រួល និងផ្តល់នូវមតិយោបល់កែលម្អបន្ថែម។ ចំពោះកាលបរិច្ឆេទនៃការជួបជុំគ្នា ត្រូវតែមានការឯកភាពគ្នា តាមសហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗ ផ្អែកលើផែនការសិក្សា និងកំណត់ពេលវេលាជាក់លាក់ណាមួយ ដែលសមាជិកទាំងអស់អាចចូលរួមបានទាំងអស់គ្នា។ ការជួបជុំគ្នាត្រូវធ្វើឡើងរៀងរាល់សប្តាហ៍ ដោយអនុវត្តបួនដងក្នុងមួយខែ និងមានការឯកភាពយកថ្ងៃណាមួយតាមការជាក់ស្តែង។

ឧទាហរណ៍៖ ក្រុមមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា

- ព្រឹកថ្ងៃសុក្រ ពីម៉ោង ៧ និង៣០នាទី ដល់ម៉ោង១០ និង៣០នាទី

ក្រុមមុខវិជ្ជាគីមីវិទ្យា ជីវវិទ្យា

- រសៀលថ្ងៃពុធ ពីម៉ោង ១ និង៣០នាទី ដល់ម៉ោង៤ និង៣០នាទី

ការប្រជុំ អាចធ្វើឡើងតាមរយៈការប្រជុំផ្ទាល់ ឬតាមប្រព័ន្ធអេឡិចត្រូនិច ដូចជា Zoom ឬ Google Meet ជាដើម។ ចំពោះទីតាំងប្រជុំ អាចកំណត់យកនៅក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ឬធ្វើនៅទីតាំងខាងក្រៅដែលផ្តល់ផាសុ-ខភាព និងមានភាពងាយស្រួលដល់សមាជិកទាំងអស់។ ប្រធានក្រុម និងអ្នកសម្របសម្រួល ត្រូវជម្រាបជូនដល់សមាជិកខ្លួននូវរបៀបវារៈប្រជុំ និងជូនព័ត៌មានទៅគណៈគ្រប់គ្រងគ្រឹះស្ថានរបស់ខ្លួន ដើម្បីជាព័ត៌មានផង និងជាការអញ្ជើញឱ្យចូលរួមស្តាប់ ឬផ្តល់មតិយោបល់ជុំវិញការសិក្សាឱ្យបានមុនមួយសប្តាហ៍។ ក្នុងករណីមានមេរៀន ឯកសារយោង ត្រូវផ្ញើជូនដល់សមាជិកខ្លួនសម្រាប់អានមុនពេលចូលរួមការប្រជុំ។ រាល់ពេលប្រជុំត្រូវមានរបាយការណ៍ ឬកំណត់ហេតុ ដើម្បីរក្សាទុកជាឯកសារ ឬភស្តុតាងក្នុងអង្គភាព ហើយសមាជិកម្នាក់ៗត្រូវចងក្រងខ្លឹមសារ និងរក្សាទុកក្នុងកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន (Teacher Trainer Portfolio)។

### ខ. ការសង្កេតថ្នាក់ និងប្រឹក្សា

ប្រធានក្រុមសហគមន៍សិក្សាដែលត្រូវបានជ្រើសរើស ត្រូវមានតួនាទីបន្ថែមទៀត គឺជាគ្រូប្រឹក្សាសម្រាប់សហគមន៍សិក្សានីមួយៗ ហើយត្រូវសហការជាមួយនាយករងទទួលបន្ទុកបច្ចេកទេស ដែលជាគ្រូប្រឹក្សាប្រចាំគ្រឹះស្ថានបណ្តុះបណ្តាល ដើម្បីផ្តល់ដំបូន្មាន និងការគាំទ្រដល់គ្រូឧទ្ទេសធ្វើការអភិវឌ្ឍវិជ្ជាជីវៈ និងធានាបាននូវប្រសិទ្ធភាពនៃការបង្រៀន និងរៀន។ ការចុះសង្កេតថ្នាក់ត្រូវមានឧបករណ៍សង្កេត និងមានផែនការច្បាស់លាស់ដោយផ្អែកលើកម្មវិធីបង្រៀនជាក់ស្តែង។ ការសង្កេតថ្នាក់ត្រូវធ្វើឡើងក្នុងសប្តាហ៍ទី១ ទី២ និងទី៣ ដោយជ្រើសរើសយកគ្រូឧទ្ទេសដែលទើបផ្ទេរចូលថ្មី ឬមានបទពិសោធន៍តិច ហើយធ្វើការបូកសរុបការងារ នៅរៀងរាល់ចុងសប្តាហ៍ទីបីនៃខែនីមួយៗ។ ព័ត៌មានដែលទទួលបានពីការសង្កេតថ្នាក់ គឺសម្រាប់ធ្វើការឆ្លុះបញ្ចាំងការសង្កេតលើកក្រោយៗទៀត ហើយក៏អាចក្លាយជាប្រធានបទ សម្រាប់ដាក់ចូលក្នុងរបៀបវារៈប្រជុំក្នុងខែនីមួយៗផងដែរ។ លើសពីនេះទៀត គ្រូប្រឹក្សាដែលជាប្រធានក្រុមសហគមន៍សិក្សា ត្រូវចាត់សមាជិករបស់ខ្លួនម្នាក់ៗ ឱ្យចូលសង្កេតការបង្រៀនរបស់គ្រូឧទ្ទេស ដែលមានបច្ចេកទេសខ្ពស់ ឱ្យបានពីរដងក្នុងមួយខែ ដើម្បីសិក្សាអំពីរបៀបច្នៃប្រឌិតវិធីសាស្ត្រសមស្របតាមមេរៀននីមួយៗ និងលទ្ធភាពជាក់ស្តែងនៃថ្នាក់នីមួយៗ។ រាល់ព្រឹត្តិបត្តិសង្កេត

ថ្នាក់ត្រូវមានការឯកភាពពីគ្រូឧទ្ទេសដែលបានសង្កេត និងត្រូវរក្សាទុកដើម្បីជាភស្តុតាងក្នុងកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន (Teacher Portfolio)។

## ៦. សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូវិទ្យាល័យ និងអនុវិទ្យាល័យ

### ៦.១. សមាសភាព

សាលារៀនមធ្យមសិក្សាចំណេះទូទៅ ត្រូវរៀបចំសហគមន៍សិក្សាវិជ្ជាជីវៈ ដោយប្រើប្រាស់ក្រុមបច្ចេកទេសតាមមុខវិជ្ជាឯកទេសដូចគ្នាដែលមានស្រាប់។ ប្រសិនបើសាលារៀនមធ្យមសិក្សាចំណេះទូទៅនោះ មានចំនួនគ្រូបង្រៀនតិច គាត់អាចសហការជាមួយសាលាជិតខាង ដែលមានចម្ងាយមិនឱ្យលើស៣គីឡូម៉ែត្រ។ សហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗត្រូវមានប្រធានក្រុមម្នាក់ និងអ្នកសម្របសម្រួលម្នាក់ ជ្រើសរើសក្នុងចំណោមសមាសភាពនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗ។ ប្រធានក្រុម និងអ្នកសម្របសម្រួល គឺជាអ្នកមានបទពិសោធន៍ការងារ មានបច្ចេកទេស កម្រិតវប្បធម៌ និងមានស្មារតីទទួលខុសត្រូវលើសមាជិកសហគមន៍សិក្សាវិជ្ជាជីវៈរបស់ខ្លួន។ ក្នុងអង្គភាពសាលារៀន ប្រធានក្រុម និងអ្នកសម្របសម្រួល អាចជាគ្រូបង្រៀនល្អ គ្រូបង្រៀនឈានមុខ ឬគ្រូបង្រៀនថ្មី ដែលទទួលបានពានរង្វាន់ស្នាដៃការងារបង្រៀន និងរៀន។ ប្រធានក្រុម និងអ្នកសម្របសម្រួលត្រូវធ្វើការជ្រើសរើសដោយការតែងតាំង ឬបោះឆ្នោត និងធ្វើការផ្លាស់ប្តូរមុនឆ្នាំសិក្សានីមួយៗ។ ចំនួន និងសមាសភាពរបស់សហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗ អាចប្រែប្រួលតាមការជាក់ស្តែង។ ករណីមុខវិជ្ជាដែលមានគ្រូបង្រៀនតិចជាង០៥នាក់ នាយកសាលាអាចចាត់បញ្ចូលគ្នាជាមួយក្រុមបច្ចេកទេសផ្សេងទៀត តាមការជាក់ស្តែង។

ឧទាហរណ៍៖ - ក្រុមបច្ចេកទេសភូមិវិទ្យា ប្រវត្តិវិទ្យា

- ក្រុមបច្ចេកទេសគីមីវិទ្យា ជីវវិទ្យា
- ក្រុមបច្ចេកទេសគណិតវិទ្យា រូបវិទ្យា
- ក្រុមបច្ចេកទេសភាសាខ្មែរ សីលធម៌-ពលរដ្ឋវិជ្ជា

ករណីសាលាមធ្យមសិក្សា មានគ្រូបង្រៀនតិច នាយកសាលាអាចចែកជាពីរក្រុមមុខវិជ្ជាគឺ៖

- ក្រុមមុខវិជ្ជាវិទ្យាសាស្ត្រពិត
- ក្រុមមុខវិជ្ជាវិទ្យាសាស្ត្រសង្គម

សាលារៀនមធ្យមសិក្សាចំណេះទូទៅ ក៏អាចបង្កើតជាសហគមន៍សិក្សាវិជ្ជាជីវៈជាកម្រិតថ្នាក់ផងដែរ ដោយយកការសិក្សារបស់សិស្សធ្វើជាប្រធានបទចម្បងក្នុងការពិភាក្សានិងចែករំលែក។ ឧទាហរណ៍៖

- នៅក្នុងថ្នាក់ទី៧A គ្រូមុខវិជ្ជាផ្សេងៗអាចបង្កើតសហគមន៍ដើម្បីពិភាក្សាពីការសិក្សារបស់សិស្សណាម្នាក់ ក្រុមសិស្សណាមួយ ឬសិស្សទាំងអស់ក្នុងថ្នាក់។

ចំពោះសាលារៀនមធ្យមសិក្សាចំណេះទូទៅ ដែលមានចាប់ពីកម្រិតថ្នាក់ទី៧រហូតដល់ថ្នាក់ទី១២ ការបង្កើតឱ្យមានសហគមន៍សិក្សាវិជ្ជាជីវៈកម្រិតមុខវិជ្ជាក៏អាចធ្វើបានផងដែរ។ ឧទាហរណ៍៖

- ក្រុមមុខវិជ្ជាគីមីវិទ្យានៅកម្រិតបឋមភូមិ អាចចូលរួមបង្កើតជាសហគមន៍សិក្សាមុខវិជ្ជាគីមីវិទ្យាជាមួយគ្រូនៅកម្រិតទុតិយភូមិ

## ៦.២. តួនាទី និងភារកិច្ច

សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូបង្រៀនអនុវិទ្យាល័យ ឬវិទ្យាល័យ ត្រូវមានផែនការគោលរួមមួយដែលមានកំណត់នូវចក្ខុវិស័យ បេសកកម្មច្បាស់លាស់ និងសកម្មភាពអាទិភាព ដើម្បីសម្រេចគោលដៅដែលខ្លួនចង់បាន។ សហគមន៍នេះ ត្រូវផ្តោតលើការងារស្រាវជ្រាវប្រតិបត្តិ ការស្រាវជ្រាវគរុកោសល្យ ការស្រាវជ្រាវលើខ្លឹមសារមុខវិជ្ជាឯកទេស ការងារបង្រៀននិងរៀន ការអភិវឌ្ឍកម្មវិធីសិក្សា និងការងារគ្រប់គ្រងថ្នាក់រៀនជាដើម ដើម្បីធ្វើឱ្យសាលារៀនមានដំណើរការប្រកបដោយប្រសិទ្ធភាព។ ដូច្នេះ សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូបង្រៀននៅវិទ្យាល័យ ឬអនុវិទ្យាល័យ ត្រូវមានភារកិច្ចមួយចំនួនដូចជា៖

- សិក្សាស្រាវជ្រាវទាក់ទងការបង្រៀន និងរៀន
- អនុវត្តការសិក្សាស្រាវជ្រាវមេរៀន និងធ្វើថ្នាក់និទស្សន៍ ដើម្បីចាប់យកនូវទេពកោសល្យទៅអនុវត្តក្នុងការងារបង្រៀន និងរៀនឱ្យមានការឯកភាពគ្នា
- ចាត់តាំងសមាជិកឱ្យចូលស្តាប់ការបង្រៀន និងការអប់រំសិស្សរបស់គ្រូណាម្នាក់ ហើយផ្លាស់ប្តូរយោបល់ និងដកបទពិសោធ ដើម្បីច្នៃប្រឌិតវិធីសាស្ត្រឱ្យសមស្រប តាមមេរៀននីមួយៗ និងលទ្ធភាព ជាក់ស្តែងនៃថ្នាក់នីមួយៗ
- ចងក្រងឯកសារវិធីបង្រៀន និងយុទ្ធសាស្ត្រថ្មីៗសម្រាប់ការងារបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាព
- ចែករំលែកបទពិសោធន៍ការងារស្រាវជ្រាវ ឬប្រសិទ្ធភាពនៃការងារបង្រៀន និងរៀនដល់សមាជិក
- ធ្វើបទបង្ហាញចំណេះដឹងដែលសមាជិកទទួលបានតាមរយៈការចូលរួមវគ្គបំប៉ន ឬសិក្ខាសាលា
- ដឹកនាំថតជាវីដេអូនៃការបង្រៀនដែលប្រើវិធីបង្រៀនថ្មីៗ សម្រាប់ចែករំលែកដល់សាលាដទៃ
- ជួយសមាជិករៀបចំផែនការអភិវឌ្ឍន៍វិជ្ជាជីវៈប្រចាំឆ្នាំ តាមដានការអនុវត្ត ដើម្បីធ្វើឱ្យសម្រេចបាននូវស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន
- ជួយបំប៉ន និងលើកកម្ពស់កម្រិតវប្បធម៌ បច្ចេកទេសដល់សមាជិករបស់ខ្លួន
- ជួយសមាជិកក្នុងការអនុវត្តផែនការបង្រៀនទៅតាមកាលកំណត់ ឱ្យបានឯកភាពគ្នាទាំងវិធីសាស្ត្រទាំងខ្លឹមសារ
- ធ្វើការវិភាគលើលទ្ធផលសិក្សារបស់សិស្ស និងរកវិធីកែលម្អគុណភាពបង្រៀន និងរៀន
- កំណត់ឱ្យបានមុខសញ្ញាសិស្សរៀនយឺត និងជួយបង្រៀនបំប៉នឱ្យបានទាន់ពេលវេលា។

## ៦.៣. របៀបរបបអនុវត្តការងារ

### ក. ការសិក្សាជាក្រុម

ប្រធានក្រុម និងអ្នកសម្របសម្រួល ត្រូវសហការជាមួយគណៈគ្រប់គ្រងសាលា និងនាយករងបច្ចេកទេស ដើម្បីដឹកនាំការសិក្សា។ រាល់ការប្រជុំត្រូវមានលិខិតប្រជុំ អមដោយរបៀបវារៈប្រជុំជូនជាព័ត៌មាន ឬជាការអញ្ជើញថ្នាក់ដឹកនាំអប់រំថ្នាក់ស្រុក DTMT និងមន្ទីរ ដើម្បីជួយសម្របសម្រួល និងផ្តល់នូវមតិយោបល់កែលម្អបន្ថែម។ ចំពោះកាលបរិច្ឆេទនៃការជួបជុំគ្នាត្រូវតែមានការឯកភាពគ្នា។ សហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗត្រូវតែមានផែនការសិក្សា និងកំណត់ពេលវេលាជាក់លាក់ណាមួយ ដែលសមាជិកទាំងអស់អាចចូលរួមបានទាំងអស់គ្នា។ ការជួបជុំគ្នាត្រូវធ្វើឡើងរៀងរាល់សប្តាហ៍ ហើយអនុវត្តបួនដងក្នុងមួយខែ ដោយឯកភាពយកថ្ងៃណាមួយ

តាមការដាក់ស្តែង។ ចំពោះអនុវិទ្យាល័យដែលមានបង្កើតជាកម្រងសាលារៀន ការប្រជុំក្នុងសប្តាហ៍ទី៤ ក្នុងខែនីមួយៗ គួររៀបចំឡើងក្នុងកម្រិតកម្រង។

ឧទាហរណ៍៖ ក្រុមមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា

- ព្រឹកថ្ងៃសុក្រ ពីម៉ោង ៧ និង៣០នាទី ដល់ម៉ោង១០ និង៣០នាទី

ក្រុមមុខវិជ្ជាគីមីវិទ្យា ជីវវិទ្យា

- រសៀលថ្ងៃពុធ ពីម៉ោង ១ និង៣០នាទី ដល់ម៉ោង៤ និង៣០នាទី

ការប្រជុំអាចធ្វើឡើងតាមរយៈការប្រជុំផ្ទាល់ឬតាមប្រព័ន្ធអេឡិចត្រូនិច ដូចជា Zoom ឬ Google Meet ជាដើម។ ចំពោះទីតាំងប្រជុំ អាចកំណត់យកនៅក្នុងសាលារៀន ឬធ្វើនៅទីតាំងក្រៅសាលាដែលផ្តល់ផាសុខភាព និងមានភាពងាយស្រួល។ ប្រធានក្រុម និងអ្នកសម្របសម្រួល ត្រូវជម្រាបជូនដល់សមាជិកខ្លួននូវរបៀបវារៈប្រជុំ ហើយក្នុងករណីមានមេរៀន ឯកសារយោង ត្រូវផ្ញើជូនដល់សមាជិកខ្លួនសម្រាប់អានមុនពេលចូលរួម ឱ្យបានមួយសប្តាហ៍មុនការប្រជុំ ។ រាល់ការប្រជុំត្រូវមានរបាយការណ៍ ឬកំណត់ហេតុ ដើម្បីរក្សាទុកជាឯកសារ ឬភស្តុតាងក្នុងអង្គភាព ហើយសមាជិកម្នាក់ៗត្រូវចងក្រងខ្លឹមសារ និងរក្សាទុកក្នុងកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន (Teacher Portfolio)។

## ខ. ការសង្កេតថ្នាក់ និងប្រឹក្សា

ប្រធានក្រុមសហគមន៍សិក្សាវិជ្ជាជីវៈដែលបានជ្រើសរើស ត្រូវមានតួនាទីបន្ថែមទៀត គឺជាគ្រូប្រឹក្សាសម្រាប់សហគមន៍សិក្សានីមួយៗ ហើយត្រូវសហការជាមួយនាយករងទទួលបន្ទុកបច្ចេកទេស ដែលជាគ្រូប្រឹក្សាប្រចាំសាលារៀន ដើម្បីផ្តល់ដំបូន្មាន និងការគាំទ្រដល់គ្រូបង្រៀនធ្វើការអភិវឌ្ឍវិជ្ជាជីវៈ និងធានាបាននូវប្រសិទ្ធភាពនៃការបង្រៀននិងរៀន។ ការចុះសង្កេតថ្នាក់ត្រូវមានឧបករណ៍សង្កេត និងមានផែនការច្បាស់លាស់ដោយផ្អែកលើ កាលវិភាគបង្រៀនជាក់ស្តែង។ ការសង្កេតថ្នាក់ត្រូវធ្វើឡើងក្នុងសប្តាហ៍ទី១ ទី២ និងទី៣ ដោយចុះសង្កេតគ្រូបង្រៀនដែលទើបចេញថ្មី មានបទពិសោធន៍តិច ឬទទួលបានលទ្ធផលសិក្សាទាប ហើយធ្វើការបូកសរុបការងារនៅរៀងរាល់ចុងសប្តាហ៍ទីបីនៃខែនីមួយៗ។ ព័ត៌មានទទួលបានពីការសង្កេតថ្នាក់ គឺសម្រាប់ធ្វើការឆ្លុះបញ្ចាំងការសង្កេតលើកក្រោយៗទៀត ហើយក៏អាចក្លាយជាប្រធានបទ សម្រាប់ដាក់ចូលក្នុងរបៀបវារៈប្រជុំក្នុងខែនីមួយៗផងដែរ។ លើសពីនេះទៀត គ្រូប្រឹក្សាដែលជាប្រធានក្រុមសហគមន៍សិក្សា ត្រូវចាត់សមាជិករបស់ខ្លួនម្នាក់ៗ ឱ្យចូលសង្កេតការបង្រៀនរបស់គ្រូបង្រៀនដែលមានបច្ចេកទេសខ្ពស់ក្នុងសាលា ឬក្នុងកម្រងជាមួយគ្នា ឱ្យបានពីរដងក្នុងមួយខែ ដើម្បីរៀនសូត្រ និងច្នៃប្រឌិតវិធីសាស្ត្រឱ្យសមស្របតាមមេរៀននីមួយៗ និងលទ្ធភាពជាក់ស្តែងនៃថ្នាក់នីមួយៗ។ រាល់ព្រឹត្តិបត្តិសង្កេតថ្នាក់ត្រូវមានការឯកភាពពីគ្រូបង្រៀនដែលត្រូវបានសង្កេត និងត្រូវរក្សាទុក ដើម្បីជាភស្តុតាងក្នុងកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន (Teacher Portfolio)។

# ៧. សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូបឋមសិក្សា

## ៧.១. សមាសភាព

សាលាបឋមសិក្សា ត្រូវរៀបចំសហគមន៍សិក្សាវិជ្ជាជីវៈ ដោយប្រើប្រាស់ក្រុមបច្ចេកទេសទៅតាមកម្រិតថ្នាក់ដូចគ្នាដែលមានស្រាប់។ សហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗត្រូវមានប្រធានក្រុមម្នាក់ និងអ្នកសម្របសម្រួលម្នាក់ ជ្រើសរើសក្នុងចំណោមសមាសភាពនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗ។ ប្រធានក្រុម និងអ្នកសម្រប

សម្រួល គឺជាអ្នកមានបទពិសោធន៍ការងារ មានបច្ចេកទេស កម្រិតវប្បធម៌ និងមានស្មារតីទទួលខុសត្រូវចំពោះសមាជិកសហគមន៍សិក្សាវិជ្ជាជីវៈរបស់ខ្លួន។ ក្នុងអង្គភាពសាលារៀន ប្រធានក្រុម និងអ្នកសម្របសម្រួល អាចជាគ្រូបង្រៀនល្អ គ្រូបង្រៀនឈានមុខ ឬគ្រូបង្រៀនឆ្នើម ដែលទទួលបានពានរង្វាន់ស្នាដៃការងារក្នុងការបង្រៀន និងរៀន។ ប្រធានក្រុម និងអ្នកសម្របសម្រួល ត្រូវធ្វើការជ្រើសរើសដោយការតែងតាំង ឬបោះឆ្នោត និងធ្វើការផ្លាស់ប្តូរមុនឆ្នាំសិក្សានីមួយៗ។ ចំនួន និងសមាសភាពរបស់សហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗ អាចប្រែប្រួលតាមការជាក់ស្តែង ។ ករណីកម្រិតថ្នាក់នីមួយៗមានគ្រូបង្រៀនតិចជាង០៥នាក់ នាយកអាចចាត់បញ្ចូលគ្នាជាមួយក្រុមបច្ចេកទេសដែលមានកម្រិតថ្នាក់ជាប់គ្នា ឬបែងចែកជាពីរកម្រិតថ្នាក់តាមការជាក់ស្តែង។

ឧទាហរណ៍៖ - ក្រុមបច្ចេកទេសថ្នាក់ទី១ និងទី២

- ក្រុមបច្ចេកទេសថ្នាក់ទី៣ និងទី៤

- ក្រុមបច្ចេកទេសថ្នាក់ទី៤ និងទី៥

ករណីសាលារៀនមានគ្រូបង្រៀនតិច នាយកអាចចែកជាពីរក្រុមគឺ៖

- ក្រុមបច្ចេកទេសថ្នាក់ទី១ ទី២ និងទី៣

- ក្រុមបច្ចេកទេសថ្នាក់ទី៤ ទី៥ និងទី៦

## ៧.២. តួនាទី និងភារកិច្ច

សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូបឋមសិក្សា ត្រូវមានផែនការគោលរួមមួយ ដែលមានកំណត់នូវចក្ខុវិស័យ បេសកកម្ម និងសកម្មភាពអាទិភាពច្បាស់លាស់ ដើម្បីសម្រេចគោលដៅដែលខ្លួនចង់បាន។ សហគមន៍នេះ ត្រូវផ្តោតលើការងារស្រាវជ្រាវ ការស្រាវជ្រាវគរុកោសល្យ ការស្រាវជ្រាវលើខ្លឹមសារមុខវិជ្ជាឯកទេស ការងារបង្រៀននិងរៀន ការអភិវឌ្ឍកម្មវិធីសិក្សា និងការងារគ្រប់គ្រងថ្នាក់រៀនជាដើម ដើម្បីធ្វើឱ្យសាលារៀនមានដំណើរការប្រកបដោយប្រសិទ្ធភាព។ ដូច្នេះ សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូបង្រៀនត្រូវមានភារកិច្ចមួយចំនួនដូចជា៖

- សិក្សាស្រាវជ្រាវទាក់ទងការបង្រៀន និងរៀន
- អនុវត្តការសិក្សាស្រាវជ្រាវមេរៀន និងធ្វើថ្នាក់និទស្សន៍ ដើម្បីចាប់យកនូវទេពកោសល្យ ទៅអនុវត្តក្នុងការងារបង្រៀន និងរៀនឱ្យមានការឯកភាពគ្នា
- ចាត់តាំងសមាជិកឱ្យចូលស្តាប់ការបង្រៀន និងការអប់រំសិស្សរបស់គ្រូណាម្នាក់ ហើយផ្លាស់ប្តូរយោបល់ និងដកបទពិសោធ ដើម្បីច្នៃប្រឌិតវិធីសាស្ត្រសមស្រប តាមមេរៀននីមួយៗ និងលទ្ធភាពជាក់ស្តែងនៃថ្នាក់នីមួយៗ
- ចងក្រងឯកសារវិធីបង្រៀន និងយុទ្ធសាស្ត្រថ្មីៗសម្រាប់ការបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាព
- ចែករំលែកបទពិសោធន៍ការងារស្រាវជ្រាវ ឬប្រសិទ្ធភាពនៃការបង្រៀន និងរៀនដល់សមាជិក
- ធ្វើបទបង្ហាញស្តីពីចំណេះដឹងដែលសមាជិកទទួលបានតាមរយៈការចូលរួមវគ្គបំប៉ន ឬសិក្ខាសាលា
- ដឹកនាំថតជាវីដេអូនៃការបង្រៀនដែលប្រើវិធីបង្រៀនថ្មីៗ សម្រាប់ចែករំលែកដល់សាលារៀនដទៃ
- ជួយសមាជិករៀបចំផែនការអភិវឌ្ឍន៍វិជ្ជាជីវៈ និងឱ្យសម្រេចបាននូវស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន
- ជួយបំប៉ន និងលើកកម្ពស់កម្រិតវប្បធម៌ បច្ចេកទេសដល់សមាជិករបស់ខ្លួន

- ជួយសមាជិកក្នុងការអនុវត្តផែនការបង្រៀនទៅតាមកាលកំណត់ ឱ្យបានឯកភាពគ្នាទាំងវិធីសាស្ត្រ និងខ្លឹមសារ
- ធ្វើការវិភាគលើលទ្ធផលសិក្សារបស់សិស្ស និងរកវិធីកែលម្អគុណភាពបង្រៀន និងរៀន
- កំណត់ឱ្យបានមុខសញ្ញាសិស្សរៀនយឺត និងជួយបង្រៀនបំប៉នឱ្យបានទាន់ពេលវេលា។

## ៧.៣. របៀបរបបអនុវត្តការងារ

### ក. ការសិក្សាជាក្រុម

ប្រធានក្រុម និងអ្នកសម្របសម្រួល ត្រូវសហការជាមួយ ប្រធានកម្រង នាយក និងនាយករងបច្ចេកទេស ដើម្បីដឹកនាំការប្រជុំ។ រាល់ការប្រជុំត្រូវមានលិខិតប្រជុំ អមដោយរបៀបវារៈប្រជុំជូនជាព័ត៌មាន ឬជាការអញ្ជើញថ្នាក់ដឹកនាំអប់រំថ្នាក់ស្រុក DTMT និងមន្ទីរ ដើម្បីជួយសម្របសម្រួល និងផ្តល់នូវមតិយោបល់កែលម្អបន្ថែម។ ចំពោះកាលបរិច្ឆេទនៃការជួបជុំគ្នាត្រូវតែមានការឯកភាពគ្នា។ សហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗ ត្រូវតែមានផែនការសិក្សា និងកំណត់ពេលវេលាជាក់លាក់ណាមួយ ដែលសមាជិកទាំងអស់អាចចូលរួមបានទាំងអស់គ្នា។ ការជួបជុំគ្នាត្រូវធ្វើឡើងរៀងរាល់សប្តាហ៍ ហើយអនុវត្តបួនដងក្នុងមួយខែ ដោយធ្វើឡើងនៅថ្ងៃព្រហស្បតិ៍ ពេលព្រឹក ឬរសៀលតាមការជាក់ស្តែង។ ការប្រជុំក្នុងសប្តាហ៍ទី៤ ក្នុងខែនីមួយៗ គួរធ្វើឡើងនៅកម្រិតកម្រងសាលា។

ឧទាហរណ៍៖ កម្រងសាលារៀន "ក" មានបីក្រុមបច្ចេកទេស៖ ថ្នាក់ទី១+២ ថ្នាក់ទី៣+៤ និងថ្នាក់ទី៥+៦

- ព្រឹកថ្ងៃព្រហស្បតិ៍ ពីម៉ោង ៧ និង៣០នាទី ដល់ម៉ោង១០ និង៣០នាទី ស្របពេលគ្នា

កម្រងសាលារៀន "ខ" មានពីរក្រុមបច្ចេកទេស៖ គឺកម្រិតទាប និងកម្រិតខ្ពស់

- ព្រឹកថ្ងៃព្រហស្បតិ៍ ពីម៉ោង ៧ និង៣០នាទី ដល់ម៉ោង១០ និង៣០នាទី សម្រាប់កម្រិតទាប
- រសៀលថ្ងៃព្រហស្បតិ៍ ពីម៉ោង ១ និង៣០នាទី ដល់ម៉ោង៤ និង៣០នាទី សម្រាប់កម្រិតខ្ពស់

ការប្រជុំ អាចធ្វើឡើងតាមរយៈការប្រជុំផ្ទាល់ ឬតាមប្រព័ន្ធអេឡិចត្រូនិច ដូចជា Zoom ឬ Google Meet ជាដើម។ ចំពោះទីតាំងប្រជុំ អាចកំណត់យកនៅក្នុងសាលារៀន សាលាកម្រង ឬធ្វើនៅទីតាំងក្រៅសាលា ដែលផ្តល់ផាសុខភាព និងមានភាពងាយស្រួល។ ប្រធានក្រុម និងអ្នកសម្របសម្រួល ត្រូវជម្រាបជូនដល់សមាជិកខ្លួននូវរបៀបវារៈប្រជុំ ហើយក្នុងករណីមានមេរៀន ឯកសារយោង ត្រូវផ្ញើជូនដល់សមាជិកខ្លួនសម្រាប់អានមុនពេលចូលរួម ឱ្យបានមួយសប្តាហ៍មុនការប្រជុំ ។ រាល់ប្រជុំ ត្រូវមានរបាយការណ៍ ឬកំណត់ហេតុ ដើម្បីរក្សាទុកជាឯកសារ ឬកស្តុតាងក្នុងអង្គភាព ហើយសមាជិកម្នាក់ៗត្រូវចងក្រងខ្លឹមសារ និងរក្សាទុកក្នុងកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន (Teacher Portfolio)។

### ខ. ការសង្កេតថ្នាក់ និងប្រឹក្សា

ប្រធានក្រុមសហគមន៍សិក្សាដែលបានជ្រើសរើស ត្រូវមានតួនាទីបន្ថែមទៀត គឺជាគ្រូប្រឹក្សាសម្រាប់សហគមន៍សិក្សានីមួយៗ ហើយត្រូវសហការជាមួយនាយករងទទួលបន្ទុកបច្ចេកទេស ដែលជាគ្រូប្រឹក្សាប្រចាំសាលារៀន ដើម្បីផ្តល់ជំនួយ និងការគាំទ្រដល់គ្រូបង្រៀន ធ្វើការអភិវឌ្ឍវិជ្ជាជីវៈ និងធានាបាននូវប្រសិទ្ធភាពនៃការបង្រៀននិងរៀន។ ការចុះសង្កេតថ្នាក់ត្រូវមានឧបករណ៍សង្កេត និងមានផែនការច្បាស់លាស់ ដោយផ្អែកលើកាលវិភាគបង្រៀនជាក់ស្តែង។ ការសង្កេតថ្នាក់ត្រូវធ្វើឡើងក្នុងសប្តាហ៍ទី១ ទី២ និងទី៣ ដោយចុះសង្កេតគ្រូបង្រៀនដែលទើបចេញថ្មី មានបទបទពិសោធន៍តិច ឬទទួលបានលទ្ធផលសិក្សាទាប ហើយធ្វើការបូកសរុបការងាររៀងរាល់ចុងសប្តាហ៍ទីបីនៃខែនីមួយៗ។ ព័ត៌មានទទួលបានពីការសង្កេតថ្នាក់ គឺសម្រាប់ធ្វើការឆ្លុះបញ្ចាំង

ការសង្កេតលើកក្រោយៗទៀត ហើយក៏អាចក្លាយជាប្រធានបទ សម្រាប់ដាក់ចូលក្នុងរបៀបវារៈប្រជុំក្នុងខែនីមួយៗផងដែរ។ លើសពីនេះទៀត គ្រូប្រឹក្សាដែលជាប្រធានក្រុមសហគមន៍សិក្សា ត្រូវចាត់សមាជិករបស់ខ្លួនម្នាក់ៗ ឱ្យចូលសង្កេតការបង្រៀនរបស់គ្រូបង្រៀនណាម្នាក់ដែលមានបច្ចេកទេសខ្ពស់ក្នុងសាលា ឬក្នុងកម្រងជាមួយគ្នា ឱ្យបាន ពីរដងក្នុងមួយខែ ដើម្បីរៀនសូត្រ និងច្នៃប្រឌិតវិធីសាស្ត្រសមស្របតាមមេរៀននីមួយៗ និងលទ្ធភាពជាក់ស្តែងនៃថ្នាក់នីមួយៗ។ រាល់ព្រឹត្តិបត្តិសង្កេតថ្នាក់ត្រូវមានការឯកភាពពីគ្រូបង្រៀនដែលបានសង្កេត និងត្រូវរក្សាទុកដើម្បីជាភស្តុតាងក្នុងកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន (Teacher Portfolio)។

## សង្ខេបរបៀបអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ

| **ប្រភេទគ្រឹះស្ថាន** | **រូបភាពសហគមន៍** | **សមាសភាព** | **បេក្ខភាពប្រធាន និងអ្នកសម្របសម្រួល** |
|---|---|---|---|
| **គ្រឹះស្ថានអប់រំគ្រូ** | សហគមន៍នាយក | ប្រធាន អ្នកសម្របសម្រួល និងសមាជិក | <u>សហគមន៍នាយក</u><br>▪ ប្រធាន៖ នាយកល្អ ឈានមុខ ឬឆ្នើម<br>▪ អ្នកសម្របសម្រួល៖ នាយកល្អ ឈានមុខ ឬឆ្នើម |
| | សហគមន៍គ្រូឧទ្ទេស | | <u>សហគមន៍គ្រូឧទ្ទេស</u><br>▪ ប្រធាន៖ គ្រូឧទ្ទេសល្អ ឈានមុខ ឬឆ្នើម<br>▪ អ្នកសម្របសម្រួល៖ គ្រូឧទ្ទេសល្អ ឈានមុខ ឬឆ្នើម |
| **វិទ្យាល័យ និង អនុវិទ្យាល័យ** | សហគមន៍នាយក | ប្រធាន អ្នកសម្របសម្រួល និងសមាជិក | <u>សហគមន៍នាយក</u><br>▪ ប្រធាន៖ នាយកល្អ ឈានមុខ ឬឆ្នើម ឬគណៈអភិបាលស្រុក<br>▪ អ្នកសម្របសម្រួលករណីទី១៖ រើសក្នុងចំណោមនាយកគ្នាគាត់ដែលមានពី៧ទៅ៩នាក់ក្នុងចំណោមសាលាជិតគ្នា(ចម្ងាយមិនលើស៣គីឡូម៉ែត្រ)<br>▪ អ្នកសម្របសម្រួលករណីទី២៖ អាចស្នើទៅមន្ទីរ ឬក្រសួង ករណីរកមិនបាន |
| | សហគមន៍គ្រូ | | <u>សហគមន៍គ្រូ</u><br>▪ ប្រធាន៖ គ្រូល្អ ឈានមុខ ឬឆ្នើម<br>▪ អ្នកសម្របសម្រួល៖ គ្រូល្អ ឈានមុខ ឬឆ្នើម |
| **បឋមសិក្សា** | សហគមន៍នាយក | ប្រធាន អ្នកសម្របសម្រួល និងសមាជិក | <u>សហគមន៍នាយក</u><br>▪ ប្រធាន៖ នាយកល្អ ឈានមុខ ឬឆ្នើម ឬគណៈអភិបាលស្រុក<br>▪ អ្នកសម្របសម្រួលករណីទី១៖ រើសក្នុងចំណោមនាយកគ្នាគាត់ដែលមានពី៧ទៅ៩នាក់ជិតគ្នា (ចម្ងាយមិនលើស៣គីឡូម៉ែត្រ)<br>▪ អ្នកសម្របសម្រួលករណីទី២៖ អាចស្នើទៅមន្ទីរ ឬក្រសួង ករណីរកមិនបាន |
| | សហគមន៍គ្រូ | | <u>សហគមន៍គ្រូ</u><br>▪ ប្រធាន៖ គ្រូល្អ ឈានមុខ ឬឆ្នើម<br>▪ អ្នកសម្របសម្រួល៖ គ្រូល្អ ឈានមុខ ឬឆ្នើម |

## ៨. ប្រព័ន្ធគាំទ្រសហគមន៍សិក្សាវិជ្ជាជីវៈ

ទោះបីជាការទទួលខុសត្រូវដ៏សំខាន់សម្រាប់ការផ្តួចផ្តើមនិងការគាំទ្រដល់សហគមន៍សិក្សាវិជ្ជាជីវៈស្ថិតលើនាយកសាលានិងគ្រូបង្រៀនក៏ដោយ ថ្នាក់ដឹកនាំ និងអង្គភាពពាក់ព័ន្ធ ក៏ត្រូវមានភារកិច្ចចូលរួមគាំទ្រដល់សហគមន៍សិក្សាវិជ្ជាជីវៈ ដើម្បីឱ្យមានដំណើរការល្អ ដែលធានាបាននូវការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនឆ្លើយតបទៅនឹងគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនិងផ្តល់ការអប់រំប្រកបដោយគុណភាព។ អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ត្រូវដឹងអំពីតួនាទីរបស់ខ្លួន និងរៀបចំយន្តការគាំទ្រទាំងផ្នែកធនធានមនុស្សនិងបច្ចេកទេសថ្មីៗដល់អ្នកប្រតិបត្តិ ដើម្បីធានាបាននូវនិរន្តរភាពនៃការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមមូលដ្ឋានសាលារៀននីមួយៗ។ លើសពីនេះទៀត ការលើកទឹកចិត្តដល់អ្នកចូលរួមក៏ជាកត្តាជំរុញមួយដ៏មានប្រសិទ្ធភាព បន្ទាប់ពីពួកគេក្លាយជាសមាជិក និងបានចូលរួមសកម្មក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ។ សេចក្តីពណ៌នាខាងក្រោម នឹងរៀបរាប់អំពីតួនាទី ភារកិច្ចអ្នកពាក់ព័ន្ធ និងរបៀបលើកទឹកចិត្តដល់អ្នកចូលរួមនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ។

### ៨.១. អ្នកពាក់ព័ន្ធសំខាន់ៗ

#### ក. អង្គភាពថ្នាក់ក្រសួង

ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង សំដៅដល់នាយកដ្ឋានជំនាញដូចជានាយកដ្ឋានគោលនយោបាយ នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ នាយកដ្ឋានធានាគុណភាពអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបឋមសិក្សា គណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន គ្រូឧទ្ទេសថ្នាក់ជាតិ និងអង្គភាពពាក់ព័ន្ធដទៃទៀត ដែលមានតួនាទី និងភារកិច្ចចូលរួមគាំទ្រ ដល់ដំណើរការសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមកម្រិតសាលារៀន។ អង្គភាពថ្នាក់ក្រសួង មានតួនាទី និងទំនួលខុសត្រូវមួយចំនួនដូចជា៖

- កំណត់វិធានការគោលនយោបាយ ឬការស្រាវជ្រាវនៅកម្រិតសាលារៀន
- ធានាបាននូវចក្ខុវិស័យរួមសម្រាប់សហគមន៍សិក្សាវិជ្ជាជីវៈនិងការអនុវត្តដែលមានសង្គតភាពនៅតាមអង្គភាពសាលារៀននីមួយៗ
- តម្រង់ទិសសហគមន៍សិក្សាវិជ្ជាជីវៈដល់អ្នកអនុវត្តគ្រប់លំដាប់ថ្នាក់ ឱ្យយល់អំពីដំណើរការអនុវត្ត និងតួនាទីរបស់ខ្លួន
- បង្កើនឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ ដើម្បីលើកកម្ពស់ដល់ដំណើរការសហគមន៍សិក្សាវិជ្ជាជីវៈ
- ផ្តល់អ្នកជំនាញចូលរួម ដោយឈរលើមូលដ្ឋានចំណេះដឹង និងតម្រូវការ ដើម្បីចែករំលែកឬផ្តល់ព័ត៌មានអំពីការអនុវត្តល្អទាំងក្នុងប្រទេស និងអន្តរជាតិ
- ជួយតាមដាន និងអភិវឌ្ឍន៍សកម្មភាពសហគមន៍សិក្សាវិជ្ជាជីវៈ ដើម្បីជំរុញការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈកាន់តែល្អប្រសើរ
- ធានាឱ្យមានការផ្សារភ្ជាប់ទំនាក់ទំនងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំទៅនឹងគន្លងអាជីពគ្រូបង្រៀន
- រៀបចំផ្តល់ការលើកទឹកចិត្តដល់អ្នកចូលរួមដោយទទួលបាននូវឱកាស ឬលាភសក្ការៈផ្សេងៗ
- បណ្តុះបណ្តាលបន្ថែមនូវចំណេះដឹងថ្មីៗ ពាក់ព័ន្ធនឹងការលើកកម្ពស់ការងារបង្រៀន និងរៀន និងដំណើរការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ

- ធ្វើការវាយតម្លៃដំណើរការអនុវត្ត និងវិភាគពីតម្រូវការធនធានផ្សេងៗ ដើម្បីធ្វើឱ្យការអនុវត្តមាននិរន្តរភាព។

**ខ. មន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនីមួយៗ (PoE/DoE)**

ការិយាល័យជំនាញរបស់មន្ទីរ ត្រូវសហការរៀបចំយន្តការជាមួយ ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌនីមួយៗ ដើម្បីគាំទ្រដល់ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។ មន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌគួរមានតួនាទី និងទំនួលខុសត្រូវមួយចំនួនដូចជា៖

- ជានាបាននូវចក្ខុវិស័យរួមសម្រាប់សហគមន៍សិក្សាវិជ្ជាជីវៈនិងការអនុវត្តដែលមានសង្គតភាពនៅតាមអង្គភាពសាលារៀននីមួយៗ
- តម្រង់ទិសសហគមន៍សិក្សាវិជ្ជាជីវៈដល់អ្នកអនុវត្តគ្រប់លំដាប់ថ្នាក់ ឱ្យយល់ពីដំណើរការអនុវត្ត និងតួនាទីរបស់ខ្លួន
- គាំទ្រ ផ្នែកធនធានមនុស្ស និងសម្ភារៈដល់សហគមន៍សិក្សាវិជ្ជាជីវៈ
- វាយតម្លៃការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ភ្ជាប់ទៅនឹងគន្លងអាជីព
- បង្កើតបណ្តាញទំនាក់ទំនងរវាងសហគមន៍សិក្សាវិជ្ជាជីវៈនិងសហគមន៍មុខវិជ្ជាឯកទេសដ៏ទៅទៀត
- ចូលរួមពិនិត្យតាមដានការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមអង្គភាពសាលារៀន ដោយមានបែងចែកក្រុមទទួលបន្ទុកច្បាស់លាស់
- ជូនដំណឹងដល់ថ្នាក់ជាតិអំពីបញ្ហាទាក់ទងនឹងការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ ដោយផ្តល់របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំនៃការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈទៅថ្នាក់លើ។

**គ. គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន**

សំដៅដល់គ្រឹះស្ថានកំពុងបណ្តុះបណ្តាលគ្រូបង្រៀន ដែលមានភារកិច្ចបណ្តុះបណ្តាលដំបូងផង និងបណ្តុះបណ្តាលបន្តផង។ ក្រៅពីការរៀបចំឱ្យមានសហគមន៍សិក្សានៅក្នុងគ្រឹះស្ថានបណ្តុះបណ្តាលរបស់ខ្លួន គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ក៏ត្រូវរៀបចំឱ្យមានទំនាក់ទំនង និងយន្តការជួយដល់សហគមន៍សិក្សាតាមអង្គភាពសាលារៀនសាធារណៈផងដែរ។

គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវមានតួនាទី និងទំនួលខុសត្រូវមួយចំនួនដូចជា៖

- រៀបចំអនុវត្តដំណើរការសហគមន៍សិក្សាវិជ្ជាជីវៈរបស់ខ្លួនឱ្យមានប្រសិទ្ធភាព
- ពង្រឹងមូលដ្ឋានចំណេះដឹងស្តីពីការអភិវឌ្ឍវិជ្ជាជីវៈតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈនិងផ្សព្វផ្សាយលទ្ធផលឱ្យបានទូលំទូលាយដល់សហគមន៍សិក្សាដទៃទៀតតាមអង្គភាពសាលារៀន
- សហគមន៍សិក្សាវិជ្ជាជីវៈនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវមានទំនាក់ទំនង និងគាំទ្រផ្នែកធនធានមនុស្សដល់សហគមន៍សិក្សាវិជ្ជាជីវៈនៅតាមអង្គភាពសាលារៀន
- ជួយគាំទ្រជំនាញផ្នែកខ្លឹមសារតាមកម្មវិធីបណ្តុះបណ្តាល និងធ្វើការណែនាំឱ្យបានជាប្រចាំ
- បញ្ចូលការអភិវឌ្ឍន៍វិជ្ជាជីវៈ ឬសកម្មភាពសហគមន៍សិក្សាវិជ្ជាជីវៈទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន
- បង្កើនការយល់ដឹង និងជំនាញផ្សេងៗ ដើម្បីគាំទ្រដល់សហគមន៍សិក្សាវិជ្ជាជីវៈដូចជាជំនាញដឹកនាំ និងជំនាញសម្របសម្រួលជាដើម

- បង្កើតឧបករណ៍វាយតម្លៃ វិភាគតម្រូវការដែលនឹងជួយកំណត់បាននូវចំណុចកែលម្អសហគមន៍សិក្សាវិជ្ជាជីវៈ
- ដឹកនាំ និងលើកទឹកចិត្តដល់សិស្ស និស្សិត ឱ្យចេះអនុវត្តនូវសកម្មភាពសហគមន៍សិក្សាវិជ្ជាជីវៈ សម្រាប់យកទៅអនុវត្តនៅតាមសាលារៀនពេលចេញទៅបម្រើការងារ
- បង្កើតកម្រងស្នាដៃវិជ្ជាជីវៈ សម្រាប់នាយកគ្រឹះស្ថាន និងគ្រូឧទ្ទេសឱ្យបានច្បាស់លាស់ និងជាគម្រូសម្រាប់អង្គភាពសាលារៀនដទៃទៀត។

## ឃ. គ្រឹះស្ថានសិក្សាសាធារណៈ

គ្រឹះស្ថានសិក្សាសាធារណៈរួមមានវិទ្យាល័យ អនុវិទ្យាល័យ និងសាលាបឋមសិក្សា ដែលជាអង្គភាពមូលដ្ឋានដ៏សំខាន់ក្នុងការផលិតធនធានមនុស្ស។ ដើម្បីដឹកនាំអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំនៅនឹងកន្លែង អង្គភាពនីមួយៗត្រូវតែតាមដានឱ្យបានខ្ជាប់ខ្ជួននូវនិន្នាការអប់រំ និងគោលនយោបាយអប់រំ ទាក់ទងនឹងការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់បុគ្គលិកអប់រំ។ សាលារៀនត្រូវតែផ្តួចផ្តើមបង្កើត សម្របសម្រួល ផ្តល់ទីកន្លែង និងធនធាន ដើម្បីដឹកនាំដំណើរការសកម្មភាពសហគមន៍សិក្សាវិជ្ជាជីវៈតាមគោលការណ៍ណែនាំ។ ភាពជោគជ័យរបស់សហគមន៍សិក្សាវិជ្ជាជីវៈស្ថិតនៅលើ គ្រូបង្រៀន និងនាយកសាលា ។

### តួនាទីរបស់ប្រធានកម្រង និងគណៈគ្រប់គ្រងសាលា មានដូចខាងក្រោម៖

- ចូលរួមបង្កើតឱ្យមានសហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់នាយកសាលា ឬគណៈគ្រប់គ្រងសាលានៅមូលដ្ឋានរបស់ខ្លួន
- ជំរុញគ្រូបង្រៀនឱ្យចូលរួមនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ និងកំណត់លក្ខខណ្ឌសហគមន៍សិក្សាវិជ្ជាជីវៈ
- ដើម្បីដឹកនាំដំណើរការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនៅក្នុងអង្គភាពសាលារៀន ត្រូវពន្យល់ឱ្យគ្រូបង្រៀនអំពីសារៈសំខាន់នៃសហគមន៍សិក្សាវិជ្ជាជីវៈ
- ចូលរួមកំណត់ និងជ្រើសរើសតំណាងក្រុមបច្ចេកទេស និងគ្រូប្រឹក្សាដែលមានឆន្ទៈក្នុងការទទួលយកតួនាទីជាអ្នកសម្របសម្រួល និងដឹកនាំសហគមន៍សិក្សាវិជ្ជាជីវៈ ក្នុងឆ្នាំសិក្សានីមួយៗ
- គាំទ្រសហគមន៍សិក្សាវិជ្ជាជីវៈ ដោយការបែងចែកធនធាន និងពេលវេលាឱ្យបានសមស្របតាមការជាក់ស្តែង
- ដឹកនាំបង្កើតផែនការសិក្សាវិជ្ជាជីវៈ កម្រងស្នាដៃវិជ្ជាជីវៈសម្រាប់អង្គភាព និងគ្រូបង្រៀនម្នាក់ៗ
- រៀបចំទីកន្លែងសម្រាប់គ្រូបង្រៀនធ្វើស្វ័យសិក្សា ក្នុងសាលារៀនដោយមានទីកន្លែងសមរម្យ និងឯកសារគ្រប់គ្រាន់។

### តួនាទីរបស់គ្រូបង្រៀន

- ត្រូវបានជំរុញ និងលើកទឹកចិត្តឱ្យចូលរួមយ៉ាងសកម្មនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ ដែលជាមធ្យោបាយមួយ ដើម្បីអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន

- អនុវត្តស្វ័យសិក្សា ដើម្បីពង្រីកចំណេះដឹងបន្ថែម និងសម្រាប់យកទៅចែករំលែកក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ
- បើកទូលាយក្នុងការចែករំលែកចំណេះដឹង និងការសិក្សាបន្ថែមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ
- ចូលរួមសកម្មនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ ដើម្បីជួយដល់សមាជិកខ្លួន និងជួយលើកកម្ពស់ការងារបង្រៀន និងរៀន
- ត្រូវទទួលយកតួនាទីបន្ថែមជាអ្នកដឹកនាំនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈដើម្បីសម្របសម្រួលការរៀបចំរបៀបវារៈ និងការកំណត់លទ្ធផល
- ចុះសង្កេតការបង្រៀនរបស់សមាជិកសហគមន៍សិក្សាវិជ្ជាជីវៈ
- បង្កើតកម្រងស្នាដៃវិជ្ជាជីវៈ ក្នុងនោះមានផែនការសិក្សាវិជ្ជាជីវៈ និងសៀវភៅកត់ត្រាអាជីពជាដើម។

## ៨.២. ប្រព័ន្ធលើកទឹកចិត្តដល់សហគមន៍សិក្សាវិជ្ជាជីវៈ

### ក. បញ្ញត្តិនៃការលើកទឹកចិត្ត

ការលើកទឹកចិត្តជាកាតាលីករដ៏ចម្បងមួយ ដើម្បីធ្វើឱ្យការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈទទួលបានជោគជ័យនៅតាមសាលារៀន ។ សំណួរដែលងាយយល់គឺថា តើគ្រូបង្រៀន និងនាយកសាលានឹងរំពឹងថាទទួលបានអ្វីក្រោយពួកគេចូលរួមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ? ផ្អែកតាមទ្រឹស្តីរបស់លោក David McClelland ស្តីពីការទទួលបានតម្រូវការចាំបាច់ "The Acquired Needs Theory" បានកំណត់នូវតម្រូវការរបស់មនុស្ស។ ទ្រឹស្តីនេះ បានបែងចែកតម្រូវការរបស់បុគ្គលិកបម្រើការងារជាបីផ្នែកគឺ៖ ការទទួលបានស្នាដៃ ការទទួលបានសម្ព័ន្ធមិត្ត និងការទទួលបានអំណាច។

- **ការទទួលបានស្នាដៃ** (Need for Achievement)៖ សំដៅដល់ការសម្រេចបាននូវភាពជោគជ័យអ្វីមួយដោយការខិតខំប្រឹងប្រែង ឬចូលរួមក្នុងសកម្មភាពអ្វីមួយ។ ឧទាហរណ៍ដ៏ល្អនៃការទទួលបានស្នាដៃក្នុងអាជីពការងារអប់រំ ចំពោះគ្រូបង្រៀន និងនាយកសាលា គឺសំដៅដល់សម្រេចបាននូវលទ្ធផលសិក្សារបស់សិស្ស ដូចជាសិស្សរបស់ខ្លួនជាប់ជាសិស្សពូកែនិទ្ទេសល្អខ្ពស់ជាងគេ ឬមានចំនួនច្រើនជាងគេ ក្នុងការប្រឡងថ្នាក់ជាតិ ឬថ្នាក់អន្តរជាតិណាមួយ។ ឧទាហរណ៍ផ្សេងទៀត ដែលជាបំណងប្រាថ្នារបស់គ្រូបង្រៀន និងនាយកសាលាគឺមានការទទួលស្គាល់ក្នុងសង្គម តាមរយៈ ការទទួលបាននូវពានរង្វាន់ការងារជាថវិកា ឬពានរង្វាន់ជាប់ចំណាត់ថ្នាក់ទទួលស្គាល់ជាគ្រូល្អ នាយកល្អ ឬសាលាដែលមានបរិស្ថានស្អាតប្រចាំក្រុង ស្រុក ខេត្ត ឬប្រទេស។
- **ការទទួលបានសម្ព័ន្ធមិត្ត** (Need for Affiliation)៖ សំដៅដល់អ្នកអប់រំ ដែលបានលះបង់ពេលវេលាចូលរួមរាល់សកម្មភាពការងារ ដើម្បីបង្កើត និងថែរក្សាទំនាក់ទំនងជាមួយសហសេវិក ឬមនុស្សក្នុងអង្គភាព ឬសង្គម។ បុគ្គលិកបែបនេះ គឺស្រឡាញ់ និងចង់លើកកម្ពស់អាជីពវិជ្ជាជីវៈរបស់ខ្លួន ដោយចូលចិត្តធ្វើការងារបែបសហការ ដូចជាការងារក្រុម និងជួយអ្នកដទៃ ដោយមានទំនោរប្រកាន់ខ្ជាប់នូវបទដ្ឋាននៃវប្បធម៌អភិវឌ្ឍ ឱ្យរីកចម្រើនការងារនៅកន្លែង ឬអង្គភាពរបស់ខ្លួន។
- **ការទទួលបានអំណាច** (Need for Power)៖ អំណាចក្នុងតម្រូវការនេះ សំដៅដល់ឥទ្ធិពលរបស់ខ្លួនទៅលើមនុស្សជុំវិញ។ ដើម្បីធ្វើឱ្យមានឥទ្ធិពលលើអ្នកដទៃក្នុងអាជីពជាអ្នកអប់រំ លុះត្រាបុគ្គលនោះ ធ្វើការបង្កើតសមត្ថភាពរបស់ខ្លួនឱ្យខ្ពស់ជាងគេ ដើម្បីជួយបង្រៀន ឬណែនាំដល់គេបាន ដោយបង្ហាញនូវសីលធម៌វិជ្ជាជីវៈខ្ពង់ខ្ពស់ មានភាពជាអ្នកដឹកនាំដែលអាចធ្វើឱ្យការសិក្សាក្នុងក្រុមឱ្យទទួលបានជោគជ័យ។

ដោយសារអំណាចនៃចំណេះដឹង និងភាពជាអ្នកដឹកនាំនេះ នឹងធ្វើឱ្យអ្នកនៅជុំវិញកោតសសើរ លើកទឹកចិត្ត ឈានទៅកការបោះឆ្នោតគាំទ្របុគ្គលបែបនេះ ឱ្យក្លាយជាប្រធានក្រុម ឬជាថ្នាក់ដឹកនាំទៅថ្ងៃអនាគត។

## ខ. ការបង្កើតឱកាសដើម្បីលើកទឹកចិត្ត

ដើម្បីទទួលបានការលើកទឹកចិត្តដល់អ្នកចូលរួមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ អង្គភាពពាក់ព័ន្ធនានាត្រូវបង្កើតឱកាស និងរៀបចំការលើកទឹកចិត្តដល់អ្នកចូលរួមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ។

- **ថ្នាក់ជាតិ**
    - គួរមានការរៀបចំវេទិកា ដូចជាសន្និសិទ និងសិក្ខាសាលាប្រចាំឆ្នាំតាមប្រធានបទ ឬកម្រិតថ្នាក់ ហើយសមាសភាពសហគមន៍សិក្សាវិជ្ជាជីវៈ អាចចូលរួមជាវាគ្មិន ដើម្បីចែករំលែកការអនុវត្ត ឬលទ្ធផលនៃការសិក្សាស្រាវជ្រាវអប់រំ
    - ជំរុញឱ្យមានការបោះពុម្ពផ្សាយឯកសារ សៀវភៅទាក់ទងទៅនឹងប្រសិទ្ធភាពនៃការប្រតិបត្តិ និងកិច្ចការស្រាវជ្រាវ
    - គួរមានយន្តការផ្តល់ផ្នែកបច្ចេកទេស និងថវិកាដូចជាលំហូរថវិកាសម្រាប់ដំណើរការសហគមន៍សិក្សាវិជ្ជាជីវៈ នៅតាមមូលដ្ឋាន ដែលប្រធានក្រុម និងអ្នកសម្របសម្រួលសហគមន៍សិក្សាវិជ្ជាជីវៈ អាចចុះជួយដល់សហគមន៍សិក្សាវិជ្ជាជីវៈដទៃទៀត
    - រៀបចំគណៈវាយតម្លៃការចូលរួមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈជាក្រេឌីត ដែលជាលក្ខខណ្ឌមួយសម្រាប់វង្វាយតម្លៃគ្រូបង្រៀន និងនាយកសាលារៀនចូលក្នុងគន្លងអាជីព
    - ផ្តល់ឱកាសឱ្យអ្នកដឹកនាំ ឬគ្រូបង្រៀនមានស្នាដៃល្អ រកឃើញចំណេះដឹងថ្មី បានចូលរួមក្នុង វគ្គបំប៉នកម្រិតជាតិ ឬអន្តរជាតិ។
- **ថ្នាក់ខេត្ត/ស្រុក (PoE/DoE)**
    - គួរមានការរៀបចំវេទិកា ដូចជាសន្និសិទ និងសិក្ខាសាលាប្រចាំឆមាស ឬត្រីមាស តាមប្រធានបទ ឬកម្រិតថ្នាក់ ហើយសមាសភាពសហគមន៍សិក្សាវិជ្ជាជីវៈ អាចចូលរួមជាវាគ្មិន ដើម្បីចែករំលែកការអនុវត្ត ឬលទ្ធផលនៃការសិក្សាស្រាវជ្រាវអប់រំ
    - រៀបចំក្រុម និងយន្តការចុះជួយ និងពិនិត្យតាមដានការអនុវត្ត និងដំណើរការសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមមូលដ្ឋានសាលារៀន ដើម្បីធានាបាននូវប្រសិទ្ធភាព និងនិរន្តរភាព
    - ធ្វើបញ្ជីឈ្មោះ និងបញ្ជូនឈ្មោះគ្រូបង្រៀន និងនាយកសាលាដែលគ្រប់លក្ខខណ្ឌចូលគន្លងមកថ្នាក់ក្រសួង។
- **អង្គភាពសាលារៀន**
    - រៀបចំឱ្យមានបរិស្ថានសិក្សាក្នុងអង្គភាពរបស់ខ្លួន ដោយមានទីកន្លែងសមរម្យសម្រាប់បុគ្គលិកអប់រំត្រៀមកិច្ចការបង្រៀនសិស្សផង និងធ្វើស្វ័យសិក្សាផង ដើម្បីទទួលបានចំណេះដឹងថ្មីៗយកទៅចែករំលែកក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ
    - បង្កើតគណៈកម្មការវាយតម្លៃលើភស្តុតាងបុគ្គលិកអប់រំ ដើម្បីចូលក្នុងគន្លងអាជីពគ្រូបង្រៀន
    - ធ្វើវង្វាយតម្លៃតម្រូវការបុគ្គលិក និងរៀបចំកម្មវិធីសហគមន៍សិក្សាវិជ្ជាជីវៈ ឱ្យឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង
    - រក្សាទុករាល់កម្រងស្នាដៃសាលារៀន និងគ្រូបង្រៀនសម្រាប់ជាភស្តុតាងក្នុងការវាយតម្លៃ។

## ៩. សេចក្តីសន្និដ្ឋាន

គោលបំណងរបស់វិស័យអបរំ គឺកសាងសង្គមមួយដែលផ្អែកលើចំណេះដឹង ឬហៅថាសង្គមពុទ្ធិ។ ក្នុងន័យនេះ វិស័យអប់រំត្រូវបានគេរំពឹងថា នឹងផលិតធនធានមនុស្ស និងមូលធនមនុស្ស ដើម្បីបម្រើការអភិវឌ្ឍជាតិ។ តាមរយៈការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ គ្រូបង្រៀននិងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា អាចរៀនសូត្របានពីគ្នា ចែករំលែកបទពិសោធន៍ ស្វែងរកចំណេះដឹងថ្មី បង្កើតវប្បធម៌សិក្សាជាមួយគ្នានៅនឹងកន្លែង និងរួមគ្នាបង្កើនលទ្ធផលសិក្សារបស់សិស្ស ដើម្បីឱ្យគ្រឹះស្ថានសិក្សាមានសមត្ថភាពផ្តល់សេវាអប់រំកាន់តែប្រសើរឡើង និងដើម្បីឱ្យសហគមន៍កាន់តែជឿជាក់លើសមត្ថភាពរបស់អ្នកផ្តល់សេវាអប់រំ។ សៀវភៅណែនាំស្តីពីការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនេះ សង្កត់ធ្ងន់លើគ្រឹះស្ថានសិក្សាសាធារណៈកម្រិតបឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ មធ្យមសិក្សាបច្ចេកទេស និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដោយសំដៅទៅលើមុខសញ្ញាដែលជា គណៈគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ គ្រូបង្រៀន និងគ្រូឧទ្ទេស។

ដោយផ្អែកលើលទ្ធផលដែលទទួលបានតាមរយៈការការអនុវត្តក្នុងតំបន់និងអន្តរជាតិ ភាពបន្សុីគ្នានៃគោលនយោបាយដែលមានស្រាប់ និងភាពមានកម្រិតនៃការអភិវឌ្ឍវិជ្ជាជីវៈនៅតាមសាលារៀន ការបង្កើតឱ្យមានសហគមន៍សិក្សាវិជ្ជាជីវៈគឺពិតជាសំខាន់និងចាំបាច់ សម្រាប់បង្កើនសមត្ថភាពគណៈគ្រប់គ្រងសាលា សមត្ថភាពបង្រៀនរបស់គ្រូ និងលទ្ធផលសិក្សារបស់សិស្ស។ សៀវភៅណែនាំស្តីពីការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនេះ នឹងដើរតួនាទីជាផែនទីបង្ហាញផ្លូវសម្រាប់បុគ្គលិកអប់រំទាំងអស់ឱ្យបង្កើតវប្បធម៌រៀននៅនឹងកន្លែង។ ការអនុវត្តជាក់ស្តែង គ្រឹះស្ថានសិក្សាសាធារណៈនីមួយៗឬនៅជិតគ្នា ត្រូវចេះមានភាពបត់បែង និងសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ ទៅតាមបរិបទ និងស្ថានភាពរបស់ខ្លួន។